CDRI
Cambodia Development Resource Institute

IOM UN MIGRATION | ASIA REGIONAL MIGRATION PROGRAM

# ការប្រែប្រួលអាកាសធាតុ និងលំនាំនៃការធ្វើចំណាកស្រុក៖ លទ្ធផលស្រាវជ្រាវនៅឃុំក្នុងខេត្តបីផ្សេងគ្នានៃប្រទេសកម្ពុជា

នង-មុនិន្ទ ស៊ាន-ច័ន្ទមុន្នី ខាន់-ដូនីរ៉ា ញ៉ុង-សូដារី
ប៊ុណ្ណាត-ហ្សូអ៊ីស៊ីជាណា សូ-លីហុង និង ងិន-ច័ន្ទរិទ្ធ



របាយការណ៍ស្រាវជ្រាវ
ខែមករា ឆ្នាំ២០២៤

របាយការណ៍ស្រាវជ្រាវ

# ការប្រែប្រួលអាកាសធាតុ និងលំនាំនៃការធ្វើចំណាកស្រុក៖ លទ្ធផលស្រាវជ្រាវនៅឃុំក្នុងខេត្តបីផ្សេងគ្នានៃប្រទេសកម្ពុជា

នង-មុនិន្ទ ស៊ាន-ច័ន្ទមុន្នី ខាន់-ដូនីរ៉ា ញ៉ុង-សូដាវី
ប៊ុណ្ណាត-ហ្សូអ៊ីស៊ីដាណា សូ-លីហុង និង ឌិន-ច័ន្ទរិទ្ធ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ភ្នំពេញ ខែមករា ឆ្នាំ២០២៤

© ២០២៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI)

**ការប្រែប្រួលអាកាសធាតុ និងលំនាំនៃការធ្វើចំណាកស្រុក៖ លទ្ធផលស្រាវជ្រាវនៅឃុំក្នុងខេត្តបីផ្សេងគ្នានៃប្រទេសកម្ពុជា**

**សូមយោងឯកសារនេះថា៖**

Nong Monin, Sean Chanmony, Khan Donira, Nhong Sodavy, Bunnath Zoe Sidana, So Lyhong and Ngin Chanrith. 2024. *Climate Change and Migration Patterns: Findings at the Commune Level in Rural Provinces of Cambodia.* CDRI Research Report. Phnom Penh: CDRI.

**វិទ្យាស្ថាន** CDRI
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
ទូរសារ៖ +៨៥៥២៣ ៨៨០៧៣៤
អ៊ីមែល៖ cdri@cdri.org.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ ចាន់ថា

# មាតិកា


សេចក្តីសង្ខេប ..... vii

១. សេចក្តីផ្តើម ..... ១
 ១.១ សាវតា ..... ១
 ១.២ គោលបំណង ..... ៣

២. ការយល់ឃើញពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការធ្វើចំណាកស្រុក ..... ៤

៣. ក្របខណ្ឌស្រាវជ្រាវ និងវិធីសាស្ត្រ ..... ១០

៤. លទ្ធផលស្រាវជ្រាវ ..... ១៥
 ៤.១ លក្ខណៈរបស់អ្នកឆ្លើយតប ជាជនចំណាកស្រុក ..... ១៥
  ៤.១.១ ប្រវត្តិរូបនៃជនចំណាកស្រុក ..... ១៥
  ៤.១.២ កម្រិតវប្បធម៌ ..... ១៦
  ៤.១.៣ ប្រភេទនៃការធ្វើចំណាកស្រុក ..... ១៧
  ៤.១.៤ ប្រភេទការងារ និងគោលដៅចំណាកស្រុក ..... ១៨
  ៤.១.៥ ប្រាក់ចំណូលនៅតាមគោលដៅចំណាកស្រុកនីមួយៗ ..... ២០
  ៤.១.៦ បណ្តាញនៃការងារចំណាកស្រុក ..... ២១
 ៤.២ ភាពប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ..... ២១
  ៤.២.១ ប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ..... ២១
  ៤.២.២ ការយល់ឃើញរបស់ប្រជាពលរដ្ឋក្នុងតំបន់ ចំពោះការរងផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ..... ២២
 ៤.៣ សមត្ថភាពបន្សាំ ..... ២៤
  ៤.៣.១ លទ្ធភាពទទួលបានធនធានតាមឃុំ ..... ២៤
  ៤.៣.២ ការចូលរួមអភិវឌ្ឍន៍ឃុំ ..... ២៥
  ៤.៣.៣ តួនាទី និងទំនួលខុសត្រូវក្នុងការអភិវឌ្ឍសហគមន៍ ..... ២៦
  ៤.៣.៤ ការទទួលបានការគាំទ្រពីសហគមន៍ ..... ២៧
  ៤.៣.៥ យុទ្ធសាស្ត្រឆ្លើយតប និងសមត្ថភាពបន្សាំខ្លួនរបស់សហគមន៍មូលដ្ឋាន ..... ២៨
  ៤.៣.៦ ប្រភពព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ..... ២៩
 ៤.៤ កត្តាចម្បងមានឥទ្ធិពលលើការធ្វើចំណាកស្រុក ..... ៣០
 ៤.៥ ការផ្លាស់ប្តូរលំនាំជីវភាពរស់នៅ និងមូលហេតុ ..... ៣២

៥. ការពិភាក្សា ..... ៣៣
 ៥.១ ផលប៉ះពាល់រយៈពេលវែងនៃការប្រែប្រួលអាកាសធាតុ ..... ៣៣
 ៥.២ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវភាពរស់នៅជនបទ ..... ៣៤
 ៥.៣ លក្ខណៈ និងស្ថានភាពនៃការចំណាកស្រុក ..... ៣៤
 ៥.៤ ទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក ..... ៣៥

៦. សេចក្តីសន្និដ្ឋាន និងការអនុវត្តគោលនយោបាយ ..... ៣៦

ដែនកំណត់នៃការសិក្សា ..... ៣៧

ឯកសារយោង ..... ៣៨

បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ..... ៤១

# បញ្ជីរូបភាព និងតារាង


រូបភាពទី ១៖ ផែនទីមាត្រដ្ឋានភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ក្នុងបណ្តាប្រទេសតាមបណ្តោយទន្លេមេគង្គ ..... ៦
រូបភាពទី ២៖ និន្នាការចំណាកស្រុកក្នុងប្រទេសកម្ពុជាឆ្នាំ១៩៩៨-២០១៩ ..... ៧
រូបភាពទី ៣៖ ក្របខណ្ឌស្រាវជ្រាវ ការប្រែប្រួលអាកាសធាតុ ..... ១០
រូបភាពទី ៤៖ ផែនទីនៃទីតាំងសិក្សា ..... ១៤
រូបភាពទី ៥៖ កម្រិតវប្បធម៌តាមភេទ ..... ១៧
រូបភាពទី ៦៖ ប្រភេទនៃចំណាកស្រុកតាមភេទ ..... ១៨
រូបភាពទី ៧៖ ប្រភេទនៃការងារតាមភេទ ..... ១៩
រូបភាពទី ៨៖ គោលដៅនៃការធ្វើចំណាកស្រុកតាមភេទ ..... ១៩
រូបភាពទី ៩៖ បណ្តាញការងារចំណាកស្រុកតាមយេនឌ័រ ..... ២១
រូបភាពទី១០៖ ប្រភេទមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុដែលអ្នកស្រុកបានជួបប្រទះក្នុងរយៈពេលដប់ឆ្នាំកន្លងមក តាមឃុំ ..... ២២
រូបភាពទី១១៖ លទ្ធភាពទទួលបានធនធានតាមឃុំសង្កាត់ ..... ២៥
រូបភាពទី១២៖ ការចូលរួមអភិវឌ្ឍន៍ឃុំ ..... ២៦
រូបភាពទី១៣៖ តួនាទីសំខាន់ៗក្នុងការប្រជុំសហគមន៍តាមឃុំ ..... ២៧
រូបភាពទី១៤៖ ការគាំទ្រក្នុងសហគមន៍ ..... ២៧
រូបភាពទី១៥៖ របៀបដោះស្រាយរបស់សហគមន៍មូលដ្ឋាន ទៅនឹងការខាតបង់ដោយអាកាសធាតុតាមឃុំ ..... ២៨
រូបភាពទី១៦៖ ប្រភពព័ត៌មានអំពីការប្រែប្រួលអាកាសធាតុតាមឃុំ ..... ២៩
រូបភាពទី១៧៖ កត្តាចម្បងនៃការធ្វើចំណាកស្រុកតាមឃុំ ..... ៣០
រូបភាពទី១៨៖ កត្តាដែលប៉ះពាល់ដល់ការធ្វើចំណាកស្រុកតាមឃុំ ..... ៣១
រូបភាពទី១៩៖ មូលហេតុនៃការផ្លាស់ប្តូរជីវភាពតាមឃុំ ..... ៣២

តារាងទី ១៖ និន្នាការចំណាកស្រុកអន្តរជាតិនៅកម្ពុជា ..... ៨
តារាងទី ២៖ សំណាក និងទំហំសំណាក ..... ១២
តារាងទី ៣៖ របាយសំណាកសរុបតាមឃុំនីមួយៗ ..... ១៤
តារាងទី ៤៖ ប្រវត្តិរូបនៃសមាជិកគ្រួសារជាជនចំណាកស្រុកតាមឃុំ ..... ១៦
តារាងទី ៥៖ ប្រាក់ចំណូលសរុបតាមគោលដៅចំណាកស្រុក និងភេទ (គិតជាដុល្លារក្នុងមួយខែ) ..... ២០
តារាងទី ៦៖ កម្រិតនៃផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះដែលអ្នកក្នុងតំបន់យល់ឃើញ ..... ២៣

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) សម្រាប់ការសិក្សានេះ។ របាយការណ៍នេះបានទទួលផលប្រយោជន៍ពីជំនាញ និងជំនួយរបស់សហការីជាច្រើននៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI ។ សូមថ្លែងអំណរគុណដល់អ្នកស្រីបណ្ឌិត ឃឹម គឹមបួយ លោកស្រីប៉ុន ដូរីណា និង លោកម៉ៅ សូសែងភិរុណ អ្នកឆ្លើយសំណួរក្នុងគ្រួសារ និងជនបង្គោលសំខាន់ៗជាច្រើននាក់ផងដែរ ដែលមិនបានលើកឡើងជាលក្ខណៈបុគ្គលចំពោះ ការរួមចំណែកដ៏សំខាន់របស់ពួកគេនៅក្នុងដំណាក់កាលផ្សេងៗនៃការសិក្សា។ យើងក៏សូមថ្លែងអំណរគុណចំពោះ បណ្ឌិត សុខ សិរី និង បណ្ឌិត យិន សូរិយា សម្រាប់ការពិនិត្យយ៉ាងយកចិត្តទុកដាក់ លើសេចក្តីព្រាងរបាយការណ៍តាំងពីដំបូងមក។ ជាចុងក្រោយ សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រដល់កញ្ញា Jess Kalisiak និង លោក អ៊ុំ ចាន់ថា សម្រាប់ការកែសម្រួល ពិនិត្យ និងសម្រួលដល់ការអភិវឌ្ឍ និងការបោះពុម្ពរបាយការណ៍នេះ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CSO | អង្គការសង្គមស៊ីវិល |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| IDMC | មជ្ឈមណ្ឌលតាមដានការផ្លាស់ទំនៅក្នុងស្រុក |
| IPCC | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| KII | សម្ភាសន៍ជនបង្គោល |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PDoWRAM | មន្ទីរធនធានទឹក និងឧតុនិយម |
| UN DESA | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម នៃអង្គការសហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ |
| WBG | ធនាគារពិភពលោក |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |

# សេចក្តីសង្ខេប

ការធ្វើចំណាកស្រុក បង្ខំឱ្យប្រជាជនក្នុងតំបន់ស្វែងរកការងារបន្ថែមទៀតដើម្បីបង្កើនប្រាក់ចំណូល សម្រាប់ទ្រទ្រង់ជីវភាព និងរក្សាសន្តិសុខស្បៀងក្នុងពេលការប្រែប្រួលបរិស្ថានកំពុងកើតឡើង។ ក្រៅពីផលិតកម្មកសិកម្ម ការប្រែប្រួលអាកាសធាតុក៏បានជះឥទ្ធិពលលើសន្តិសុខស្បៀង សុខភាព ធនធានទឹក និងថាមពល ព្រមទាំងបណ្តាលឱ្យមានចំណាកស្រុក និងជម្លោះផងដែរ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើបុរស និងស្ត្រី ក៏អាចមានលក្ខណៈខុសគ្នា ទៅតាមការងារ ការគ្រប់គ្រងធនធានធម្មជាតិ បទដ្ឋានសង្គម ផ្នត់គំនិតយេនឌ័រ ឱកាសសេដ្ឋកិច្ចសង្គម និងការសម្របខ្លួនទៅនឹងបច្ចេកវិទ្យាថ្មីៗ។ ការបំភាយនូវឧស្ម័នផ្ទះកញ្ចក់ពីចង្វាក់ផលិតកម្ម វិស័យដឹកជញ្ជូន និងការប្រើប្រាស់ថាមពល នឹងកើនឡើងនៅក្នុងតំបន់ទីក្រុង ដែលបណ្តាលមកពីការអភិវឌ្ឍន៍ផ្សេងៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធជាដើម។ ទន្ទឹមនឹងនេះ ដីកសិកម្ម និងសកម្មភាពកសិកម្មមួយចំនួននៅតំបន់ជនបទ អាចនឹងត្រូវប្រឈមទៅនឹងការបោះបង់ចោលដោយសារការធ្វើចំណាកស្រុកទៅកាន់ទីក្រុង ឬប្រទេសជិតខាង។ ជាងនេះទៅទៀត ការជំពាក់បំណុល គឺជាមូលហេតុចម្បងមួយដែលធ្វើឱ្យអ្នកភូមិតាមតំបន់ដាច់ស្រយាលទាំងប្រុសទាំងស្រី ធ្វើចំណាកស្រុកទៅរកការងារធ្វើនៅទីក្រុង។ ហេតុផលនៅពីក្រោយបំណុលទាំងនេះ អាចទាក់ទងយ៉ាងខ្លាំងទៅនឹងការខូចខាតដំណាំ ដែលបណ្តាលមកពីគ្រោះមហន្តរាយ ឬព្រឹត្តិការណ៍អាកាសធាតុពាក់ព័ន្ធផ្សេងទៀត។ ការធ្វើចំណាកស្រុក គឺដាក់បន្ទុកបន្ថែមលើម្តាយចាស់ជរា ឬជីដូនដែលនៅផ្ទះមើលថែទាំកូនៗ និងចៅៗ បន្ថែមលើការងារផ្ទះផ្សេងៗជាច្រើនទៀតដែលពួកគាត់កំពុងរ៉ាប់រ៉ងស្រាប់។

តាមរយៈការប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ ការសិក្សានេះបានអង្កេតពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក នៅក្នុងឃុំចំនួនបីក្នុងខេត្តក្រចេះ មណ្ឌលគិរី និងខេត្តស្ទឹងត្រែង នៃប្រទេសកម្ពុជា។ ទិន្នន័យត្រូវបានប្រមូលពី២៤០គ្រួសារ នៃប្រជាជនដែលមានសមាជិកចំណាកស្រុក។ ការសិក្សានេះមានគោលបំណងពីរគឺ (១) ដើម្បីស្វែងយល់ពីនិន្នាការអតីតកាល និងបច្ចុប្បន្នភាពនៃធាតុអាកាស និងលំនាំនៃការធ្វើចំណាកស្រុកនៅក្នុងសហគមន៍ជនបទរបស់កម្ពុជា និង (២) ដើម្បីវិភាគពីរបៀបដែលការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់លំនាំនៃការធ្វើចំណាកស្រុក និងណែនាំនូវវិធីសាស្ត្រឆ្លើយតបប្រកបដោយនិរន្តរភាព ដែលសមស្របទៅនឹងបទដ្ឋាននៃសហគមន៍មូលដ្ឋាន។

ការសិក្សានេះបង្ហាញថា ការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុកមានទំនាក់ទំនងគ្នា។ សីតុណ្ហភាពបានកើនឡើង ហើយរដូវប្រាំង និងរដូវវស្សាបានប្រែទៅជាមិនទៀងទាត់។ ការបាត់បង់ចំណូលដែលបណ្តាលមកពីភាពខូចខាតនៃដំណាំដោយសារកត្តាព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ក៏ជាមូលហេតុមួយ ដែលបណ្តាលឱ្យមានការធ្វើចំណាកស្រុក។ ជាធម្មតាប្រជាជនធ្វើចំណាកស្រុកក្នុងរយៈពេលខ្លី ដើម្បីរកដំណោះស្រាយផ្គត់ផ្គង់ជីវភាព។ ក្រោយពីទទួលបានប្រាក់កម្រៃគ្រប់គ្រាន់ហើយ អ្នកភូមិត្រឡប់ទៅធ្វើស្រែចម្ការវិញ។ ភាគច្រើននៃជនចំណាកស្រុក ជាប្រជាជនស្ថិតនៅក្នុងអាយុធ្វើការ ហើយភាគច្រើនធ្វើ ចំណាកស្រុកទៅកាន់រាជធានី ឬខេត្តផ្សេងៗ ដើម្បីធ្វើការក្នុងរោងចក្រកាត់ដេរ ឬការដ្ឋានសំណង់ ឬធ្វើការងារលើកដាក់ប្រើកម្លាំងពលកម្ម។

កត្តាគោលនយោបាយហាក់ដូចជាមិនសូវមានឥទ្ធិពល លើការធ្វើចំណាកស្រុក និងលំនាំនៃការធ្វើចំណាកស្រុកឡើយ។ ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជាគ្រោះរាំងស្ងួត កំណើនសីតុណ្ហភាព គ្រោះទឹកជំនន់ និងខ្យល់ព្យុះ មិនត្រូវបានយល់ឃើញថា ជាដើមហេតុដោយផ្ទាល់នៃការធ្វើចំណាកស្រុកនោះទេ ទោះបីជាអ្នកភូមិខ្លះប្រឈមមុខនឹងបន្ទុកគ្រួសារ ភាពជាប់អាស្រ័យ និងបញ្ហាសុខភាព ក៏ដោយក្តី ពួកគេជឿថាកត្តាទាំងនោះ ទំនងជាមិនរួមចំណែកដល់ការធ្វើចំណាកស្រុកនោះទេ។ ការសិក្សានេះបានរកឃើញថា កត្តាជំរុញផ្នែកសង្គម និងសេដ្ឋកិច្ច គឺជាកត្តាសំខាន់ដែលជំរុញ

ឱ្យមនុស្សធ្វើចំណាកស្រុក។ កត្តាទាំងនេះរួមមានភាពក្រីក្រ ការជំពាក់បំណុល ការផ្ទេរកន្លែងធ្វើការទៅកន្លែងផ្សេង ការស្វែងរកការងារត្រឹមត្រូវ អសន្តិសុខស្បៀង ភាពអត់ការងារធ្វើ ការបាត់បង់ដីធ្លី ឬផ្ទះសម្បែង និងទិន្នផលដំណាំថយចុះជាដើម។

ការសិក្សានេះបានសន្និដ្ឋានថា ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ គឺជាមូលហេតុនៃការបាត់បង់ និងការខូចខាត ទ្រព្យសម្បត្តិ ដំណាំ បសុសត្វ និងបសុបក្សី ដែលនាំឱ្យបាត់បង់ប្រាក់ចំណូល និងនាំឱ្យកើតមានភាពក្រីក្រ។ ភាពក្រីក្រ និងការជាប់បំណុលជំរុញយ៉ាងខ្លាំងឱ្យសមាជិកគ្រួសារធ្វើចំណាកស្រុក ដើម្បីស្វែងរកឱកាសការងារដែលប្រសើរជាងមុន។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅក្នុងស្រុក និងកាត់បន្ថយការធ្វើចំណាកស្រុក អនុសាសន៍ខាងក្រោមត្រូវបានលើកឡើង៖

(១) ផ្តល់ការបណ្តុះបណ្តាលស្តីពីការអនុវត្តកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ

(២) ផ្តល់ប្រព័ន្ធធារាសាស្ត្រ និងផ្តល់ការបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់ផលិតកម្មកសិកម្ម និងទិន្នផល ធ្វើពិពិធកម្ម កសិកម្ម និងបង្កើនការងារកសិកម្មក្នុងស្រុក

(៣) បង្កើនការចូលរួមថ្នាក់មូលដ្ឋាន និងការចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការអភិវឌ្ឍន៍សហគមន៍ និងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តឆ្ពោះទៅរកការបង្កើនភាពធន់នឹងអាកាសធាតុ។

# ១
# សេចក្តីផ្តើម

## ១.១ សាវតា

របាយការណ៍វាយតម្លៃទីប្រាំមួយរបស់ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានបង្ហាញថា ការធ្វើចំណាកស្រុកស្ថិតនៅក្នុងចំណោមបញ្ហាប្រឈមបំផុតដែលកំពុងកើតមាន។ គ្រោះថ្នាក់ដែលបណ្តាលមកពីព្រឹត្តិការណ៍អាកាសធាតុ រួមមានកំណើនសីតុណ្ហភាព ការប្រែប្រួលកម្រិតនៃកម្ពស់ទឹកភ្លៀង ការប្រែប្រួលដែលគួរឱ្យកត់សម្គាល់នៃរបបខ្យល់មូសុង កំណើននីវ៉ូទឹកសមុទ្រ ទឹកជំនន់ និងព្យុះស៊ីក្លូនត្រូពិច កំពុងតែមានការកើនឡើងប្រេកង់ និងកម្រិតធ្ងន់ធ្ងរ (Cruz et al., ២០០៧)។ មុខសញ្ញាគ្រោះថ្នាក់ដែលត្រូវបានពណ៌នានេះ បានជះផលទៅលើកម្រិតនៃការធ្វើចំណាកស្រុក នៅក្នុងចំណោមនិន្នាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមផ្សេងទៀត ព្រមទាំងបង្កើនការព្យាករណ៍សម្រាប់ពេលអនាគតផងដែរ។ ជាលទ្ធផល ការធ្វើចំណាកស្រុកត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើមាត្រដ្ឋានសកម្មភាពអាកាសធាតុ ទាក់ទងនឹងអន្តរាគមន៍ឆ្លើយតប និងយុទ្ធសាស្ត្របន្សាំ (IPCC, ២០២៣)។ នៅតំបន់អាស៊ីអាគ្នេយ៍ ការប្រែប្រួលអាកាសធាតុកំពុងតែធ្វើឱ្យខូចខាត ហើយផ្នែកផ្សេងៗនៃតំបន់កាន់តែងាយរងគ្រោះទៅនឹងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ជាពិសេសគ្រោះរាំងស្ងួត ការបាក់ដី ទឹកជំនន់ និងព្យុះស៊ីក្លូន (Yusuf & Francisco, ២០០៩)។ អាស្រ័យហេតុនេះ ព្រឹត្តិការណ៍គ្រោះថ្នាក់ទាំងនេះបានជះឥទ្ធិពលអវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជន និងបង្កឱ្យមានបញ្ហាសង្គមផ្សេងៗរួមមាន ការបាត់បង់ដីធ្លី ការខូចខាត ឬបាត់បង់លំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធ ដំណាំ និងសត្វពាហនៈ និងចំណាកស្រុកជាដើម (Haque, ១៩៩៧)។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការធ្វើចំណាកស្រុកបានក្លាយទៅជា ការឆ្លើយតបមួយក្នុងជម្រើសចុងក្រោយរបស់ប្រជាជនមូលដ្ឋាន ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលបរិស្ថាន និងការប្រែប្រួលអាកាសធាតុ (Tacoli, ២០០៩)។ ការសិក្សារបស់ Édes នៅក្នុងឆ្នាំ២០១២ បានបង្ហាញពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក។ ការសិក្សានេះបានបង្ហាញថា លំហូរនៃការធ្វើចំណាកស្រុកត្រូវបានចាត់ទុកថាកើតឡើងញឹកញយ ស្ថិតនៅខាងក្រៅឆន្ទៈរបស់ប្រជាជន ដែលក្នុងនោះ ប្រជាជនដែលរស់នៅក្នុងតំបន់ដែលងាយនឹងរងផលប៉ះពាល់ទៅនឹងអាកាសធាតុ នឹងត្រូវបង្ខំឱ្យផ្លាស់ទីលំនៅទៅកាន់តំបន់ផ្សេងទៀត (Mastrorillo et al., ២០១៦)។ ប្រជាជន ត្រូវបានបង្ខំឱ្យធ្វើចំណាកស្រុកទៅកាន់តំបន់ផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយភ្លាមៗ និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ (Naik, ២០០៩) និងការប្រែប្រួលបរិស្ថានដែលកើតឡើងបន្តិចម្តងៗ ឬចាប់ផ្តើមយឺតៗ (ឧទាហរណ៍ កំណើននីវ៉ូទឹកសមុទ្រ ការរិចរិលគម្របដី ការបាត់បង់ព្រៃឈើ និងវាលរហោស្ថានកម្ម (Leighton, ២០០៩)។ ការធ្វើចំណាកស្រុកដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ កើតឡើងទាំងបណ្តោះអាសន្ន (ឧទាហរណ៍ នៅពេលដែលមនុស្សភៀសខ្លួន អំឡុងពេលមានព្យុះខ្លាំង ឬគ្រោះរាំងស្ងួត ប៉ុន្តែត្រលប់មកវិញនៅពេលព្រឹត្តិការណ៍នេះបានស្ងប់ទៅវិញ) ឬជាអចិន្ត្រៃយ៍ (ឧទាហរណ៍ នៅពេលដែលតំបន់ណាមួយដូចជា សហគមន៍មូលដ្ឋាន ទីប្រជុំជន ឬ ប្រទេស ដែលបានក្លាយជាតំបន់ដែលមនុស្សមិនអាចរស់នៅបាន) (Docherty & Giannini, ២០០៩)។

នៅប្រទេសកម្ពុជា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បានបង្ហាញឱ្យឃើញនូវគ្រោះថ្នាក់នៃអាកាសធាតុ ដូចជា ទឹកជំនន់ និងភាពរាំងស្ងួត ដែលប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍវិស័យកសិកម្ម (Sok et al., ២០២១)។ លោក Chihh et al., ឆ្នាំ២០២៣ បានបញ្ជាក់ថា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើប្រជាជននៅតាមជនបទ ដោយកត្តាគ្រោះរាំងស្ងួតបានក្លាយទៅជាព្រឹត្តិការណ៍កាន់តែធ្ងន់ធ្ងរ និងកើតមានជាញឹកញាប់ជាងមុន។ នេះអាចប៉ះពាល់ដល់កម្រិតខ្ពស់នៃអត្រាចំណាកស្រុកក្នុង និងក្រៅប្រទេសរបស់កម្ពុជា។ របាយការណ៍ជំរឿនទូទៅប្រជាជននៅកម្ពុជាឆ្នាំ២០១៩ បង្ហាញថាការធ្វើចំណាកស្រុកពីជនបទទៅទីប្រជុំជន (៣៤%)

មានទំហំធំជាងការធ្វើចំណាកស្រុកពីប្រជុំជនមួយទៅទីប្រជុំជនមួយទៀត (៣០%) ពីជនបទទៅជនបទ (២៩%) ឬការធ្វើចំណាកស្រុកពីទីប្រជុំជនទៅជនបទ (៣០%) (NIS, ២០២០)។ របាយការណ៍នេះបានបង្ហាញថាមូលហេតុនៃការធ្វើចំណាកស្រុក រួមមាន ការផ្លាស់ប្តូរទីលំនៅជាមួយគ្រួសារពួកគេ (៤៤,៩%) ការស្វែងរកការងារធ្វើ (១៩,៤%) អាពាហ៍ពិពាហ៍ (១៤,៩%) ការស្វែងរកឱកាសការងារធ្វើ (៩,១%) និងការអប់រំ (២,៣%)។ ជាក់ស្តែង ប្រជាជនមួយចំនួនធ្វើចំណាកស្រុកដោយសារការបាត់បង់ដីធ្លីឬផ្ទះសំបែង គ្រោះធម្មជាតិ ការក្លាយជាកុមារកំព្រា និងភាពអសន្តិសុខ ប៉ុន្តែការប្រែប្រួលអាកាសធាតុមិនត្រូវបានបញ្ជាក់ថាជាហេតុផលនៃការធ្វើចំណាកស្រុកទេ(NIS, ២០២០)។

អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានធ្វើការស្រាវជ្រាវមួយនៅក្នុងឆ្នាំ២០០៩ និងបានរកឃើញថាភាពតានតឹងផ្នែកបរិស្ថាន និងសម្ពាធពីការធ្វើចំណាកស្រុក បង្ខំប្រជាជនក្នុងតំបន់ជនបទឱ្យស្វែងរកដំណោះស្រាយបន្ថែមទៀត ក្នុងការបង្កើនប្រភពប្រាក់ចំណូល ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ និងសន្តិសុខស្បៀងស្របពេលដែលមានការប្រែប្រួល (IOM, ២០០៩)។ តាមរយៈការសិក្សាដ៏ទូលំទូលាយរបស់ លោក Goh ឆ្នាំ២០១២ បានបង្ហាញថា ការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់វិសមភាពយេនឌ័រ ទៅលើទ្រព្យសម្បត្តិ ក្នុងនោះទាក់ទងនឹងភាពមិនសមាមាត្រគ្នាលើភាពជាម្ចាស់ និងការគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះ ក៏ដូចជាភាពខុសគ្នានៃកម្រិតសុខុមាលភាពរបស់បុរស និងស្ត្រី។ ការធ្វើចំណាកស្រុក គឺជាផ្នែកមួយក្នុងចំណោមផលប៉ះពាល់ដទៃសំខាន់ៗ រួមជាមួយនឹងផលិតកម្មកសិកម្ម សន្តិសុខស្បៀង សុខភាព និងធនធានទឹក និងថាមពល។ ជាលទ្ធផលនៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ សម្ពាធកាន់តែខ្លាំងត្រូវបានដាក់លើភាពអសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុង ហើយជាលទ្ធផល ការបំភាយឧស្ម័នផ្ទះកញ្ចក់ ពីការផលិត ការដឹកជញ្ជូន និងការប្រើប្រាស់ថាមពលនឹងកើនឡើងនៅក្នុងតំបន់ទីក្រុង (Goh,២០១២)។ ទន្ទឹមនឹងនោះ ដីកសិកម្ម និងសកម្មភាពធ្វើកសិកម្មនៅតំបន់ជនបទអាចនឹងត្រូវបោះបង់ចោល ដោយសារការធ្វើចំណាកស្រុកទៅកាន់ទីក្រុង។

ការសិក្សាមួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB បានបង្ហាញថា ការជាប់ជំពាក់បំណុល គឺជាមូលហេតុចម្បងមួយដែលនាំឱ្យអ្នកភូមិដាច់ស្រយាលទាំងប្រុស និងស្រីធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនៅក្នុងទីក្រុង (ADB, ២០១៨)។ ហេតុផលនៅពីក្រោយការជំពាក់បំណុល អាចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងទិន្នផលដំណាំថយចុះដែលត្រូវបានបំផ្លាញដោយព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ និងមីក្រូអាកាសធាតុ (Microclimates)។ របាយការណ៍បានបន្ថែមទៀតថា ចលនាចំណាកស្រុកដ៏ច្រើនសន្ធឹកសន្ធាប់នេះ បានដាក់បន្ទុកបន្ថែមលើ ម្តាយចាស់ ឬជីដូនក្នុងការមើលថែកូននិងចៅ និងមើលថែទាំងការងារផ្ទះផ្សេងៗក្នុងពេលដំណាលគ្នា (ADB, ២០១៨)។ ការសិក្សាមួយទៀតរបស់ Parsons and Nielsen (២០២០) បានរកឃើញទំនាក់ទំនងដ៏ជិតស្និទ្ធរវាងការយល់ឃើញពីការប្រែប្រួលអាកាសធាតុ និងលំនាំនៃការធ្វើចំណាកស្រុករបស់គ្រួសារនៅតំបន់ដាច់ស្រយាល ស្ថិតនៅជុំវិញបឹងទន្លេសាប និងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ទន្លេមេគង្គ។ ដូចគ្នានេះដែរ លោក Nong (២០២១) បានរកឃើញថាប្រជាជនក្នុងខេត្តបាត់ដំបង ជ្រើសរើសទៅធ្វើការនៅតាមទីក្រុងផ្សេងៗ និងនៅតាមព្រំដែនប្រទេសថៃ ជាលក្ខណៈតាមរដូវកាល នៅពេលដែលគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់កើតឡើង។ គោលបំណងចម្បងនៃការធ្វើចំណាកស្រុក គឺដើម្បីរកប្រាក់ និងផ្ញើប្រាក់ទៅផ្ទះ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ (Sok & Yang, ២០២១)។ ខណៈពេលដែលជនចំណាកស្រុកប្រឈមមុខនឹងស្ថានភាពការងារ និងជីវភាពដែលមិនអាចទទួលយកបាននោះ Sok (២០១៩) អំពាវនាវឱ្យមានយន្តការសមស្របដើម្បីកែលម្អលក្ខខណ្ឌទាំងនេះ ពីព្រោះការធ្វើចំណាកស្រុកបានក្លាយជាយុទ្ធសាស្ត្រគ្រួសារដើម្បីកាត់បន្ថយហានិភ័យ និងបង្កើនប្រាក់ចំណូលអតិបរមាសម្រាប់យុវជននៅតាមជនបទនៅកម្ពុជា (Sok & Yang, ២០២១)។

បញ្ហាការធ្វើចំណាកស្រុក ធ្វើឱ្យមានការគិតគូរជាក់លាក់ទៅតាមបរិបទ ក្នុងការកំណត់កិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ការធ្វើចំណាកស្រុក និងសន្តិសុខស្បៀង នៅក្នុងអាទិភាពគោលនយោបាយ និងការចរចាក្រោមអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ កត្តាជាច្រើនជំរុញឱ្យមនុស្សធ្វើចំណាកស្រុក ប៉ុន្តែអ្នកវិទ្យាសាស្ត្រ អ្នកបង្កើតគោលនយោបាយ និងអ្នកស្រាវជ្រាវនៅតែមិនទាន់

យល់ច្បាស់អំពីទំនាក់ទំនងរវាងការធ្វើចំណាកស្រុក និងការប្រែប្រួលអាកាសធាតុ ដោយសារកង្វះទិន្នន័យ និងព័ត៌មានជាក់ស្តែង (ADB, ២០១២)។

នៅក្នុងបរិបទនៃការធ្វើចំណាកស្រុក ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលលើបុរស និងស្ត្រីតាមបែបផែនផ្សេងៗគ្នា ទាក់ទងនឹងការផ្លាស់ប្តូរការងារ ការគ្រប់គ្រងលើទ្រព្យសម្បត្តិ និងធនធាន បទដ្ឋានសង្គម យេនឌ័រ និងផ្នត់គំនិតសង្គម ការអភិវឌ្ឍ សេដ្ឋកិច្ចសង្គម និងការទទួលយកបច្ចេកវិទ្យាថ្មីៗ (Joarder and Miller, ២០១៣; Kaczan និង Orgill-Meyer, ២០២០; Brzoska and Fröhlich, ២០១៦)។ ការបន្សាំ និងភាពធន់គឺជាយន្តការមូលដ្ឋាន ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុដែលប៉ះពាល់ដល់ភាពក្រីក្រនៅតាមជនបទ និងសន្តិសុខស្បៀង (Sok and Yu, ២០១៥; Sok et al., ២០១៤)។ សហគមន៍ដែលមានសមត្ថភាពបន្សាំទាប ធ្វើចំណាកស្រុកដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេបង្កដោយសារមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ។

## ១.២ គោលបំណង

ការសិក្សានេះ ធ្វើការត្រួតពិនិត្យអំពីទំនាក់ទំនងរវាងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា។ គោលបំណងរងចំនួនពីរត្រូវបានលើកឡើងបន្ថែមទៀតនៅខាងក្រោមនេះ៖

(១) ដើម្បីស្វែងយល់ពីនិន្នាការអតីតកាល និងបច្ចុប្បន្ននៃ អាកាសធាតុ និងលំនាំនៃការធ្វើចំណាកស្រុកនៅក្នុងសហគមន៍ជនបទរបស់កម្ពុជា។

(២) ដើម្បីវិភាគអំពីកត្តាជះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ទៅលើលំនាំនៃការធ្វើចំណាកស្រុក និងផ្តល់នូវវិធីសាស្ត្រឆ្លើយតបប្រកបដោយនិរន្តរភាព ដែលសមស្របទៅនឹងបទដ្ឋាននៃតំបន់ជនបទ។

# ២
# ការយល់ឃើញពីផលប៉ះពាល់នៃ ការប្រែប្រួលអាកាសធាតុលើការធ្វើចំណាកស្រុក

ការប្រែប្រួលអាកាសធាតុ គឺជាបាតុភូតដ៏ស្មុគស្មាញមួយដែលជះឥទ្ធិពលដល់ប្រព័ន្ធរូបវន្ត សង្គម និងសេដ្ឋកិច្ច។ ការប្រែប្រួលអាកាសធាតុអាចមានផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ទៅលើសុខុមាលភាពរបស់មនុស្ស ជីវភាពរស់នៅ សុខភាព សន្តិសុខ និងការអភិវឌ្ឍ។ ផលប៉ះពាល់មួយ ចំនួននៃការប្រែប្រួលអាកាសធាតុរួមមាន ការកើនឡើងសីតុណ្ហភាព និង កំណើននីវ៉ូទឹកសមុទ្រ។ គ្រោះថ្នាក់អាកាសធាតុបានធ្វើឱ្យមានការកើនឡើងនូវប្រេកង់ និងភាពធ្ងន់ធ្ងរនៃ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះ រលកកម្តៅ ភ្លើងឆេះព្រៃ កង្វះខាតទឹក អសន្តិសុខស្បៀង និងជំងឺឆ្លងតាមភ្នាក់ងារចម្លង។ មូលហេតុនៃការប្រែប្រួលអាកាសធាតុត្រូវបានសន្មតថាជាសកម្មភាពរបស់មនុស្សដែលផ្លាស់ប្តូរសមាសភាពបរិយាកាស (Goh ,២០១២)។ ការធ្វើចំណាកស្រុក គឺជាដំណើរការពហុវិមាត្រ ដែលពាក់ព័ន្ធនឹងចលនារបស់មនុស្សពីកន្លែងមួយទៅកន្លែងមួយ ទាំងក្នុងប្រទេស ឬឆ្លងកាត់ព្រំដែន។ ការធ្វើចំណាកស្រុក អាចជាការស្ម័គ្រចិត្ត ឬដោយមិនស្ម័គ្រចិត្តជាលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ វិលជុំ ឬបន្តបន្ទាប់ ទៀងទាត់ ឬមិនទៀងទាត់ និងទទួលរងឥទ្ធិពល ពីកត្តាជាច្រើនដូចជា សេដ្ឋកិច្ច សង្គម នយោបាយ វប្បធម៌ បរិស្ថាន និងប្រជាសាស្ត្រ (Castle et al., ២០១៤)។ ការធ្វើចំណាកស្រុកក៏អាចមានផលប៉ះពាល់ជាវិជ្ជមាន ឬអវិជ្ជមានទៅលើទាំងនៅដើមកំណើត និងតំបន់ចំណាកស្រុក អាស្រ័យលើបរិបទ និងលក្ខណៈរបស់ជនចំណាកស្រុក (Haan ១៩៩៩; Agza, Alamirew, and Shibru ២០២៣; Asfaw, Tolossa, and Zeleke ២០១០)។

ការផ្លាស់ទីលំនៅ គឺជាទម្រង់ជាក់លាក់មួយនៃការធ្វើចំណាកស្រុកដែលកើតឡើង នៅពេលដែលមនុស្សត្រូវបានបង្ខំឱ្យចាកចេញពីកន្លែងរស់នៅរបស់ពួកគេ ដោយសារតែមានការគំរាមកំហែង ឬគ្រោះថ្នាក់ណាមួយដែលកើតមានឡើងជាក់ស្តែង។ ការផ្លាស់ទីលំនៅ មានច្រើនរូបភាពដូចជា នៅក្នុងប្រទេស ឬឆ្លងព្រំដែន ចាប់ផ្តើមភ្លាមៗ ឬចាប់ផ្តើមយឺតៗ អូសបន្លាយ ឬរយៈពេលខ្លី និងបុគ្គល ឬសមូហភាព (IDMC, ២០២០)។ ការផ្លាស់ទីលំនៅ ក៏អាចមានផលប៉ះពាល់ផ្នែកមនុស្សធម៌ សិទ្ធិមនុស្ស ការអភិវឌ្ឍ និងសន្តិសុខសម្រាប់ ទាំងជនដែលផ្លាស់ទីលំនៅ និងប្រជាជនសហគមន៍ដែលរស់នៅទីនោះពីមុនមក។

ការសិក្សាមួយចំនួនបានព្យាយាមផ្តល់នូវការប៉ាន់ស្មាន ឬព្យាករណ៍អំពីការធ្វើចំណាកស្រុក ឬការផ្លាស់ទីលំនៅដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន ឬអនាគត នៅកម្រិតសកល ថ្នាក់តំបន់ ឬថ្នាក់ជាតិ។ ជាឧទាហរណ៍ របាយការណ៍មួយរបស់ធនាគារពិភពលោកបានព្យាករណ៍ថា ប្រជាជនចំនួនប្រមាណ ២១៦លាននាក់ នៅក្នុង៦តំបន់នៃពិភពលោក អាចនឹងផ្លាស់ទីលំនៅ ពីប្រទេសមួយទៅប្រទេសមួយទៀតក្នុងឆ្នាំ២០៥០ ដែលបង្កមកពីការរងផលប៉ះពាល់ដោយសារអាកាសធាតុដែលចាប់ផ្តើមយឺតៗ ដូចជា កង្វះទឹក ការខូចខាតផលដំណាំ កំណើននីវ៉ូទឹកសមុទ្រ និងខ្យល់ព្យុះ។ របាយការណ៍នេះក៏បានប៉ាន់ប្រមាណដែរថា សកម្មភាពដំបូងដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងដើម្បីធានាបាននូវការអភិវឌ្ឍ ប្រកបដោយបរិយាប័ន្ន និងភាពធន់ អាចកាត់បន្ថយអត្រានៃការធ្វើចំណាកស្រុកក្នុងប្រទេស ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងកម្រិតមួយដ៏ខ្ពស់ (Clement et al., ២០២១)។

ជាងនេះទៅទៀត មជ្ឈមណ្ឌលត្រួតពិនិត្យការផ្លាស់ទីលំនៅក្នុងស្រុក (IDMC) នៅឆ្នាំ២០២០ បានរាយការណ៍ថា នាពេលថ្មីៗនេះ ប្រជាជនប្រមាណ ២៤,៩លាននាក់ ត្រូវបានផ្លាស់ទីលំនៅដោយសារតែគ្រោះមហន្តរាយដែលបានកើតឡើងភ្លាមៗនៅក្នុង១៤០ប្រទេស និងតំបន់កាលពីឆ្នាំ២០១៩ ដែលក្នុងនោះ ២៣,៩លាននាក់ បានផ្លាស់ទីលំនៅ

ដោយសារមូលហេតុទាក់ទងនឹងអាកាសធាតុ និង ១លាននាក់បានផ្លាស់ទីលំនៅដោយសារកត្តាភូមិសាស្ត្រ។ របាយការណ៍នេះ ក៏កត់សម្គាល់ផងដែរថា គ្រោះមហន្តរាយដែលចាប់ផ្តើមយឺតៗ ដូចជា ភាពរាំងស្ងួត និងកំណើននីវ៉ូទឹកសមុទ្រ ទំនងជាបង្កឱ្យមានការផ្លាស់ទីលំនៅ ឬកាន់តែបង្កើនចំនួនការផ្លាស់ទីលំនៅនាពេលអនាគត ប៉ុន្តែទិន្នន័យ និងការវិភាគលើបាតុភូតនេះនៅមានកម្រិតនៅឡើយ (IDMC, ២០២០)។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប៉ាន់ប្រមាណថា ប្រជាជនប្រហែល ៣៧លាននាក់នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិកអាចប្រឈមនឹងហានិភ័យនៃការផ្លាស់ទីលំនៅ ដោយសារកំណើននីវ៉ូទឹកសមុទ្រនាឆ្នាំ២០៥០ ដែលក្នុងនោះ ១២លាននាក់ស្ថិតនៅក្នុងតំបន់ឆ្នេរដែលមានរយៈកំពស់ទាប និង២៥លាននាក់ស្ថិតនៅក្នុងប្រទេសកោះ ឬអាតូល។ របាយការណ៍ក៏បានណែនាំផងដែរថាការប្រែប្រួលអាកាសធាតុ អាចប៉ះពាល់ដល់លំនាំនៃការធ្វើចំណាកស្រុកក្នុងតំបន់ តាមរយៈបណ្តាញផ្សេងៗ ដូចជាការផ្លាស់ប្តូរផលិតភាពកសិកម្ម បរិមាណទឹកដែលអាចប្រើប្រាស់បាន គ្រោះមហន្តរាយធម្មជាតិ ហានិភ័យសុខភាព នគរូបនីយកម្ម និងសន្តិសុខមនុស្ស (ADB, ២០១២)។

យ៉ាងណាមិញប្រទេសកម្ពុជាទំនងជាជួបប្រទះនូវស្ថានភាពប្រហាក់ប្រហែលគ្នាដែរប៉ុន្តែនៅក្នុងបរិបទនៃប្រទេសកម្ពុជា ភស្តុតាងជាក់ស្តែងលើទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុកឬការផ្លាស់ទីលំនៅនៅមានកម្រិតនៅឡើយ។ ការស្រាវជ្រាវរបស់លោក Maltoni នៅឆ្នាំ២០១០ បានបង្ហាញឱ្យឃើញថាការធ្វើចំណាកស្រុកបានប៉ះពាល់ជាចម្បងទៅលើការផ្ញើរប្រាក់ និងសេដ្ឋកិច្ចសង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាមួយចំនួន បានបង្ហាញថាប្រទេសកម្ពុជាមានភាពងាយរងគ្រោះខ្លាំង ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយសារទីតាំងភូមិសាស្ត្រ សមត្ថភាពបន្សុាំទាប និងការពឹងផ្អែកខ្លាំងលើធនធានធម្មជាតិ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសំខាន់ៗមួយចំនួន ដែលអាចប៉ះពាល់ដល់ការធ្វើ ចំណាកស្រុក ឬការផ្លាស់ទីលំនៅនៅកម្ពុជា រួមមាន៖ (១) កំណើនសីតុណ្ហភាព និងការប្រែប្រួលនៃកម្ពស់ទឹកភ្លៀង ដែលអាចប៉ះពាល់ដល់ផលិតកម្មកសិកម្ម សន្តិសុខស្បៀង បរិមាណទឹកដែលអាចប្រើប្រាស់បាន និងសុខភាព (២) ការកើនឡើងនៃភាពញឹកញាប់ ឬប្រេកង់ និងអាំងតង់ស៊ីតេនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលអាចបំផ្លាញ ហេដ្ឋារចនាសម្ព័ន្ធ និងជីវភាព (៣) កំណើននីវ៉ូទឹកសមុទ្រ និងជម្រាបនៃទឹកប្រៃ អាចគំរាមកំហែងដល់តំបន់ឆ្នេរ តំបន់ព្រៃកោងកាង ធនធានជលផល និងធនធានទឹកសាប។

ការសិក្សារបស់ លោក Clement et al ឆ្នាំ២០២១ បានបង្ហាញថាប្រទេសកម្ពុជា គឺជាប្រទេសមួយ នៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលត្រូវបានព្យាករណ៍ថានឹងជួបប្រទះការធ្វើចំណាកស្រុកនៅក្នុងប្រទេស ដោយសារតែផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលចាប់ផ្តើមបន្តិចម្តងៗ ដូចជា កង្វះទឹក ការខូចខាតនៃផលដំណាំ កំណើននីវ៉ូសមុទ្រ និងការកញ្ច្រោលនៃព្យុះ។ បើគ្មានសកម្មភាពឆ្លើយតបគ្រប់គ្រាន់ទៅនឹងការប្រែប្រួលអាកាសធាតុ អាចនឹងមានប្រជាជនកម្ពុជារហូតដល់ ១,៥លាននាក់ (ឬ ៩% នៃចំនួនប្រជាជនសរុប) ត្រូវបានផ្លាស់ទីលំនៅនៅក្នុងប្រទេសនៅឆ្នាំ២០៥០ ដែលភាគច្រើនមកពីតំបន់ជនបទដែលពឹងផ្អែកលើវិស័យកសិកម្ម និងធនធានធម្មជាតិ (Clement et al , ២០២១)។ របាយការណ៍នេះ ក៏កំណត់តំបន់គោលដៅសក្តានុពលមួយចំនួន ដែលជាទីតាំងគោលដៅរបស់ប្រជាជនដែលធ្វើចំណាកស្រុកដោយមូលហេតុអាកាសធាតុ មានដូចជាតំបន់ទីក្រុង និងតំបន់ដែលមានរយៈកម្ពស់ខ្ពស់ ដែលជាកន្លែងអាចផ្តល់ឱកាសសេដ្ឋកិច្ច ច្រើនជាងមុន និងលទ្ធភាពទទួលបានសេវាកម្មប្រសើរជាងមុន។ ជាងនេះទៅទៀត Sigelmann (២០២០) ដែលជាអ្នកធ្វើការវិភាគលើភាពងាយរងគ្រោះនៃអាកាសធាតុថ្នាក់ក្រោមជាតិ និងទំនាក់ទំនងរវាងបរិមាណទឹកដែលអាចប្រើប្រាស់បាន និងការធ្វើចំណាកស្រុកក្នុងប្រទេសកម្ពុជា បានរកឃើញថាទឹកភ្លៀងកំពុងថយចុះនៅភាគពាយព្យនៃប្រទេសកម្ពុជា ជាទីតាំងដែលប្រជាជនភាគច្រើនពឹងផ្អែកខ្លាំងលើការធ្វើកសិកម្មដំណាំស្រូវ។

ការសិក្សាដោយ Jacobson et al. (២០១៨) ដោយសហការជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការក្រៅរដ្ឋាភិបាលក្នុងខេត្តជុំវិញបឹងទន្លេសាបនៃប្រទេសកម្ពុជាបានបង្ហាញថា រហូតដល់ទៅ ៤៥% នៃគ្រួសារប្រជាជនកម្ពុជា មានសមាជិកម្នាក់ដែលធ្វើចំណាកស្រុក ហើយជាងពាក់កណ្តាលនៃប្រជាជនទាំងនោះបានបង្ហាញថាភាពតានតឹងទាក់ទងនឹងអាកាសធាតុ ជាមូលហេតុនៃការធ្វើចំណាកស្រុកចេញពីភូមិឃុំរបស់ពួកគេ។ ជាងនេះទៅទៀត គេបាន

រកឃើញថាការធ្វើចំណាកស្រុកបណ្តាលឱ្យមានកង្វះកម្លាំងពលកម្ម និងបញ្ហាសុខុមាលភាពនៅក្នុងភូមិរបស់ពួកគេ ប៉ុន្តែមិនធ្វើឱ្យសន្តិសុខស្បៀងប្រសើរឡើងនោះទេ។ ការធ្វើចំណាកស្រុកអាចជាយុទ្ធសាស្ត្រឆ្លើយតបរយៈពេលវែង ហើយការប្រែប្រួលអាកាសធាតុធ្វើឱ្យមនុស្សធ្លាក់ក្នុងភាពក្រីក្រ (Jacobson, ២០១៨)។

ដើម្បីវាយតម្លៃភាពងាយរងគ្រោះ និងការឆ្លើយតបរបស់កម្ពុជាចំពោះការផ្លាស់ប្តូរបរិស្ថាន Oudry et al. (២០១៦) បានផ្តោតលើខេត្តចំនួនពីរក្នុងអាងទន្លេសាប ដែលជាតំបន់មានប្រជាជនភាគច្រើនពឹងផ្អែកលើការនេសាទ ឬកសិកម្មសម្រាប់ផ្គត់ផ្គង់ជីវភាពរបស់ពួកគេ។ ការសិក្សាបានរកឃើញថា ការរិចរិលធនធានធម្មជាតិ និងបរិស្ថាន និងគ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ គឺជាកត្តាជំរុញចម្បងនៃការធ្វើចំណាកស្រុកនៅតំបន់បឹងទន្លេសាប។ ការធ្វើចំណាកស្រុក ដើរតួជាយុទ្ធសាស្ត្របន្សាំសម្រាប់គ្រួសារជាច្រើន ប៉ុន្តែបង្កបញ្ហាប្រឈមដូចជាសមាហរណកម្មសង្គម និងសេដ្ឋកិច្ច ការការពារសិទ្ធិមនុស្ស និងនិរន្តរភាពបរិស្ថាន។

យោងតាមរបាយការណ៍ IPCC នាពេលថ្មីៗនេះបានអះអាងថា តំបន់អាស៊ី រាប់ទាំងប្រទេសកម្ពុជា គឺប្រឈមនឹងហានិភ័យខ្ពស់ទៅនឹងការប្រែប្រួលអាកាសធាតុ ដែលកម្រិតនៃភាពធ្ងន់ធ្ងរនោះនឹងអាស្រ័យទៅលើវិសាលភាពនៃកំណើនកម្តៅផែនដី (Chaturvedi et al., ២០២២)។ តំបន់នេះប្រឈមនឹងគ្រោះថ្នាក់ផ្សេងៗ រួមទាំងរលកកម្តៅខ្លាំង កង្វះទឹក និងភ្លៀងធ្លាក់ខ្លាំង ដែលទាំងអស់នេះអាចជះឥទ្ធិពលអាក្រក់ដល់សុខភាពមនុស្ស ការផលិតអាហារ និងលទ្ធភាពទទួលបានទឹក។ នៅពេលដែលសីតុណ្ហភាពផែនដីកើនឡើង ភាពងាយរងគ្រោះចំពោះបញ្ហាទាក់ទងនឹងទឹក ក៏នឹងកើនឡើងផងដែរ។ ជាពិសេសតំបន់អាស៊ីកណ្តាលនឹងជួបប្រទះភាពគ្រោះរាំងស្ងួតកាន់តែធ្ងន់ធ្ងរ គុណភាពទឹកកាន់តែយ៉ាប់យ៉ឺន និងហានិភ័យកាន់តែធ្ងន់ធ្ងរ។ តំបន់អាស៊ីខាងត្បូង និងបូព៌ាបានមើលឃើញនូវកំណើននៃទឹកជំនន់ដែលបណ្តាលមកពីកំណកអាកាសច្រើន ហើយនិន្នាការនេះត្រូវបានគេព្យាករណ៍ថានឹងកើនឡើងកាន់តែខ្លាំង ស្របពេលដែលប្រទេសតំបន់ឆ្នេរ ប្រឈមនឹងកំណើននីវ៉ូទឹកសមុទ្រ ភាពកញ្ច្រោលនៃព្យុះ និងរលកដ៏ខ្លាំង (Chaturvedi et al., ២០២២)។

រូបភាពទី១៖ ផែនទីមាត្រដ្ឋាននៃភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ក្នុងបណ្តាប្រទេសតាមបណ្តោយទន្លេមេគង្គ




ប្រភព៖ (ក) WREI (២០១៥) និង (ខ) Yusuf and Francisco (២០០៩) (ដកស្រង់ពី Kuntiyawichai et al. ២០១៥)

បើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាមានភាពឈានមុខគេជាពិសេស ចំពោះភាពងាយរងគ្រោះទៅនឹងគ្រោះថ្នាក់អាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ដោយសារតែសមត្ថភាពឆ្លើយតបនៅមានកម្រិតខ្សោយ ដូចដែលបានបង្ហាញក្នុងរូបភាពទី១។ គួបផ្សំនឹងផលប៉ះពាល់នៃសកម្មភាពដែលបង្កើតឡើងដោយមនុស្ស ដូចជាការសាងសង់វារីអគ្គិសនី និងការកាប់បំផ្លាញព្រៃឈើ ផលិតភាពក្នុងទន្លេមេគង្គ និងបឹងទន្លេសាបដែលកំពុងតែរងផលប៉ះពាល់។ នេះគឺជាក្តីព្រួយបារម្ភយ៉ាងខ្លាំងចំពោះសហគមន៍ក្រីក្រ ជនបទ និងសហគមន៍តាមដងទន្លេដែលពឹងផ្អែកខ្លាំងលើធនធានទាំងនេះសម្រាប់ជីវភាព និងការផ្គត់ផ្គង់របស់ពួកគេ។ ការព្យាករណ៍អំពីការប្រែប្រួលអាកាសធាតុនាពេលអនាគតបង្ហាញថា ប្រទេសកម្ពុជានឹងជួបប្រទះនូវទឹកជំនន់ និងគ្រោះរាំងស្ងួតជាញឹកញាប់ និងធ្ងន់ធ្ងរ ដែលអាចនឹងបណ្តាលឱ្យមានការធ្លាក់ចុះយ៉ាងតិចជិត១០% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសនៅឆ្នាំ២០៥០ (World Bank, ២០២១)។

ការធ្វើចំណាកស្រុកដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំសក្តានុពលប្រជាសាស្ត្រ និងទីផ្សារការងាររបស់កម្ពុជា។ គ្រួសារនៅតាមជនបទជាច្រើន បានពឹងផ្អែកទៅលើ ការធ្វើចំណាកស្រុកជាមធ្យោបាយគោល សម្រាប់ចិញ្ចឹមជីវិត (Fitzgerald et al., ២០០៧; Maltoni, ២០១០)។ ចំណាកស្រុកបាននាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន សម្រាប់គ្រួសារទាំងនេះដូចជា លក្ខខណ្ឌលំនៅដ្ឋានដែលប្រសើរជាងមុន លទ្ធភាពទទួលបានអាហារដែលមានគុណភាពល្អជាងមុន ការបង្កើនឱកាសទទួលបានការអប់រំ ការកាត់បន្ថយភាពក្រីក្រ និងការដើរតួជាសំណាញ់សុវត្ថិភាពក្នុងអំឡុងពេលមានការប្រែប្រួលនៃប្រាក់ចំណូល (Maltoni, ២០០៦; Tong, ២០១១; Roth et al ., ២០១៥)។

រូបភាពទី២៖ និន្នាការចំណាកស្រុកក្នុងប្រទេសកម្ពុជាឆ្នាំ១៩៩៨-២០១៩




ប្រភព៖ ជំរឿនប្រជាជនជាតិឆ្នាំ ២០០៨ និងឆ្នាំ ២០១៩ (វិទ្យាស្ថានជាតិស្ថិតិ, ២០០៨ និង ២០២០)

ការធ្វើចំណាកស្រុកនៅកម្ពុជា អាចបែងចែកទៅជាការធ្វើចំណាកស្រុកនៅក្នុងប្រទេស និងឆ្លងព្រំដែន ដោយផ្អែកលើជំរឿនប្រជាជនទូទៅ។ ការធ្វើចំណាកស្រុកក្នុងប្រទេស ជាពិសេសការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង គឺជានិន្នាការលេចធ្លោមួយ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ដែលត្រូវបាន ជំរុញដោយទស្សនវិស័យ សេដ្ឋកិច្ចមានកម្រិតនៅក្នុងតំបន់ជនបទ និងការទាក់ទាញនៃឱកាសប្រសើរជាងមុននៅក្នុងទីក្រុង ដូចជា រាជធានីភ្នំពេញ (UNESCO,

២០១៦)។ យោងតាមជំរឿនប្រជាជនជាតិឆ្នាំ២០១៩ ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង ចូលរួមចំណែក ៣៤% នៃការធ្វើចំណាកស្រុកក្នុងប្រទេស ដែលលើសពីអត្រានៃការធ្វើចំណាកស្រុកពីជនបទទៅជនបទ (២៩%) ជាលើកដំបូង ដូចដែលបានបង្ហាញក្នុងរូបភាពទី២។ លំនាំនៃការធ្វើចំណាកស្រុកនេះ បានជំរុញឱ្យមានកំណើន នគរូបនីយកម្មយ៉ាងឆាប់រហ័សនៅក្នុងប្រទេស។ ការសិក្សារបស់កម្មវិធីស្បៀងអាហារពិភពលោក (WFP) ដែលធ្វើឡើងក្នុងឆ្នាំ២០១៩ ដោយបានធ្វើអង្កេតប្រជាជនចំនួន ២៣៤១គ្រួសារនៅតំបន់ជនបទ ក្នុង ១៦០ភូមិ ក្នុង២៤ខេត្ត នៃប្រទេសកម្ពុជាបានរកឃើញថា ប្រហែល ៣៥% នៃគ្រួសារនៅជនបទបានបង្ហាញថា ពួកគេមានសមាជិកយ៉ាងហោចណាស់ម្នាក់ ដែលពាក់ព័ន្ធទៅនឹងការធ្វើចំណាកស្រុក។ ក្នុងចំណោមជនចំណាកស្រុកទាំងនេះ ប្រមាណ ៤៣% ត្រូវបានចាត់ថ្នាក់ជា ជនចំណាកស្រុករយៈពេលវែង ដោយក្នុងនោះមានរយៈពេលពី ៦ខែ ដល់ ៣ឆ្នាំ។ លើសពីនេះទៀតប្រហែល ៣៣% នៃករណីធ្វើចំណាកស្រុកត្រូវបានគេរាយការណ៍ថាមានរយៈពេលខ្លី ឬតាមរដូវកាល ដោយមានរយៈពេល ៦ខែ ឬតិចជាងនេះ។

ម៉្យាងវិញទៀតការធ្វើចំណាកស្រុកឆ្លងដែន គឺជានិន្នាការសំខាន់មួយទៀតនៅក្នុងប្រទេសកម្ពុជាផងដែរដែលប្រជាជនស្វែងរកការងារ និងឱកាសសម្រាប់ចិញ្ចឹមជីវិតនៅតាមប្រទេសជិតខាង។ នៅឆ្នាំ២០២០ ជនអន្តោប្រវេសន៍កម្ពុជាប្រមាណ ១,១លាននាក់ ដែលស្មើនឹង ៦,៧៤% នៃចំនួនប្រជាជនសរុបរបស់កម្ពុជាបានធ្វើដំណើរទៅក្រៅប្រទេស ដើម្បីស្វែងរកអនាគតកាន់តែប្រសើរជាងមុន សូមមើលតារាងទី១ (UN DESA, ២០២០)។ ប្រទេសថៃ គឺជាគោលដៅដ៏ពេញនិយមសម្រាប់ពលករចំណាកស្រុកកម្ពុជា ដោយសារប្រទេសនេះមានព្រំដែនជាប់ប្រទេសកម្ពុជា និងមានតម្រូវការការងារសម្បូរបែបក្នុងវិស័យផ្សេងៗ (OECD &CDRI, ២០១៧)។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើចំណាកស្រុកក្នុងទម្រង់បែបនេះ ក៏បង្ហាញនូវបញ្ហាប្រឈមរួមទាំងបញ្ហាទាក់ទងនឹងការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងអំពើហិង្សាជាដើម (Lee, ២០០៧; Sok, ២០១៩)។

តារាងទី១៖ និន្នាការចំណាកស្រុកអន្តរជាតិនៅកម្ពុជា

| ចំណាកស្រុកអន្តរជាតិ | 2000 | 2010 | 2015 | 2020 |
|---|---|---|---|---|
| ប្រជាជនសរុប (រាប់ពាន់នាក់) | 12,119 | 14,364 | 15,418 | 16,397 |
| ចំនួនជនអន្តោប្រវេសន៍ (រាប់ពាន់នាក់) | 460 | 953 | 1,075 | 1,105 |
| % នៃជនអន្តោប្រវេសន៍នៃចំនួនប្រជាជនសរុប | 3.79% | 6.64% | 6.97% | 6.74% |
| ប្រទេសគោលដៅ (គិតជា%) | | | | |
| ប្រទេសថៃ (%) | 33% | 64% | 62% | 63% |
| ប្រទេសកូរ៉េខាងត្បូង (%) | 0% | 1% | 4% | 5% |
| ប្រទេសម៉ាឡេស៊ី (%) | 1% | 1% | 1% | 1% |

ប្រភព: UN DESA (https://www.un.org/development/desa/pd/content/international-migrant-stock)

ការសិក្សាស្រាវជ្រាវដែលបានរាយរាប់កន្លងមក បានទទួលស្គាល់ និងកត់ត្រាទុកយ៉ាងល្អពីការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ (Bylander, ២០១៥; Oudry et al., ២០១៦; Tacoli, ២០០៩)។ ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ រួមបញ្ចូលដូចជាការអនុវត្តយុទ្ធសាស្ត្រ និងវិធានការកាត់បន្ថយ និងសម្របខ្លួនទៅផលវិបាក ដោយមានគោលដៅចម្បងក្នុងការការពារសុខុមាលភាពរបស់បុគ្គល និងសហគមន៍។ សមត្ថភាពរបស់បុគ្គល និងក្រុមក្នុងការបន្សាំខ្លួនទៅនឹងភាពតានតឹងអាកាសធាតុ ត្រូវបានកំណត់ដោយកត្តាជាច្រើន ដែលរួមបញ្ចូលមានការទទួលបានធនធានហិរញ្ញវត្ថុ ព័ត៌មាន ការអប់រំ ការថែទាំសុខភាព ការគាំទ្រសង្គម ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា (Adger et al., ២០០៧)។ ប្រសិនបើការប្រែប្រួលអាកាសធាតុធ្វើឱ្យបញ្ហាសុខភាពកាន់តែធ្ងន់ធ្ងរ និងបង្កើនអត្រាមរណៈ បណ្តាល

ឱ្យមានការថយចុះនៃប្រាក់ចំណូល និងដាក់កម្រិតលើលទ្ធភាពក្នុងការទទួលបានធនធានធម្មជាតិសំខាន់ៗ បុគ្គលម្នាក់ៗអាចនឹងពិចារណាលើការធ្វើចំណាកស្រុកទៅកាន់តំបន់ដែលពួកគេយល់ថាផ្តល់ឱកាស និងជីវភាពរស់នៅដែលប្រសើរជាងមុន។ ស្ថានភាពនេះធ្វើឱ្យមានការព្រួយបារម្ភអំពីកំណើនដោយសក្តានុពលភាព និងការចល័តរបស់មនុស្សដែលជាការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ (Warner et al., ២០១០)។

ការសិក្សាជាច្រើន បានស្វែងយល់ពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុកក្នុងប្រទេសកម្ពុជា។ យ៉ាងណាមិញ ការសិក្សាភាគច្រើនបានផ្តោតលើតំបន់ជាក់លាក់មួយ ខណៈពេលដែលមើលរំលងតំបន់ភាគឦសាននៃប្រទេស។ Jacobson et al. (២០១៩) បានធ្វើការសិក្សាមួយនៅតំបន់ជនបទ នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ការសិក្សានេះបានរកឃើញថាប្រហែល ៤៥% នៃគ្រួសាររបស់អ្នកភូមិបានជ្រើសរើសធ្វើចំណាកស្រុក ហើយជាងពាក់កណ្តាលនៃចំនួនជនចំណាកស្រុកទាំងនោះ បានបង្ហាញថាបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុគឺជាមូលហេតុនៃការធ្វើចំណាកស្រុករបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ នៅមានភាពស្រពេចស្រពិលទាក់ទងនឹងចម្លើយថាតើការធ្វើចំណាកស្រុក ជាចម្បងស្ថិតនៅខាងក្នុងប្រទេស ឬខាងក្រៅប្រទេស។ Parsons and Nielson (២០២១) បានស៊ើបអង្កេតលើការយល់ឃើញពីការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុកនៅក្នុងតំបន់ទន្លេសាប និងទន្លេមេគង្គ ហើយបានរកឃើញនូវទំនាក់ទំនងដ៏ជិតស្និទ្ធរវាងការយល់ឃើញពីការប្រែប្រួលអាកាសធាតុ និងចំណាកស្រុកតាមគ្រួសារ។ Nguyen and Sean (២០២១) បានរកឃើញ ពីកំណើនកើនឡើងនៃអត្រាចំណាកស្រុកនៅក្នុងខេត្តកំពង់ចាម ជាពិសេសក្នុងចំណោមកសិករមកពីកសិដ្ឋានខ្នាតតូចនិងមធ្យម ដែលប្រឈមនឹងផលប៉ះពាល់អាកាសធាតុកាន់តែខ្លាំង។ Sigelmann (២០២០) បានពិនិត្យលើភាពងាយរងគ្រោះ នៃអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងទំនាក់ទំនងរវាងបរិមាណទឹកដែលអាចប្រើប្រាស់បាននិងការធ្វើចំណាកស្រុក។ ការសិក្សាបានរកឃើញថា គ្រួសារដែលជួបប្រទះការបាត់បង់ដំណាំ គ្រោះរាំងស្ងួត និងកម្ពស់ភ្លៀងធ្លាក់ទាប ទំនងជាមានសមាជិកគ្រួសារធ្វើចំណាកស្រុក ហើយប្រសិនបើភាគពាយព្យនៃប្រទេសកម្ពុជានៅតែបន្តជួបប្រទះភាពរាំងស្ងួត ការធ្វើចំណាកស្រុកត្រូវបានគេរំពឹងថា នឹងមានការកើនឡើងនាពេលអនាគត។ ជាចុងក្រោយ Oudry, Pak, and Chea (២០១៦) បានវាយតម្លៃលើភាពងាយរងគ្រោះ និងការឆ្លើយតបទៅនឹងការប្រែប្រួលបរិស្ថាននៅក្នុងប្រទេសកម្ពុជា ដោយផ្តោតលើទំនាក់ទំនងការផ្លាស់ប្តូរបរិស្ថាននៅក្នុងអាងទន្លេសាប។ លទ្ធផលនៃការស្រាវជ្រាវរបស់ពួកគេ បានគូសបញ្ជាក់ពីការវិចរឹលបរិស្ថាន និងគ្រោះមហន្តរាយ ទាក់ទងនឹងអាកាសធាតុ ដែលជាកត្តាជំរុញសំខាន់នៃការធ្វើចំណាកស្រុកក្នុងតំបន់ ព្រមទាំងបង្កបញ្ហាប្រឈម ចំពោះសមាហរណកម្មសង្គម និងសេដ្ឋកិច្ច ការការពារសិទ្ធិមនុស្ស និងចីរភាពបរិស្ថាន។

# ៣
# ក្របខណ្ឌស្រាវជ្រាវ និងវិធីសាស្ត្រ

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្របែបចម្រុះដោយមានការចូលរួមពីភាគីពាក់ព័ន្ធ រាប់តាំងពីអ្នកតាក់តែងគោលនយោបាយ និងអ្នកអនុវត្តគម្រោង រហូតដល់សហគមន៍មូលដ្ឋាន ចូលរួមក្នុងដំណើរការស្រាវជ្រាវ។ វិធីសាស្ត្រនេះបែងចែកជាបីជំហាន៖ (១) ការពិនិត្យមើលអត្ថបទស្រាវជ្រាវកន្លងមក និងការពិគ្រោះយោបល់ (២) ការសង្កេតនៅតាមមូលដ្ឋាន ការប្រមូលទិន្នន័យ និងការវិភាគ និង (៣) ការផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវ និងការបញ្ចប់ការស្រាវជ្រាវ។ ការចូលរួមដោយស្មើភាពរបស់ស្ត្រី និងបុរសត្រូវបានយកចិត្តទុកដាក់ជាចម្បង ដើម្បីឆ្ពោះទៅរកការយល់ដឹងស៊ីជម្រៅអំពីផលប៉ះពាល់យេនឌ័រពីការប្រែប្រួលអាកាសធាតុ។ ក្នុងដំណើរការស្រាវជ្រាវនេះ នឹងធ្វើឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់រដ្ឋាភិបាលនៅពហុកម្រិត សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ការសិក្សានេះ អនុវត្តវិធីសាស្ត្រវិភាគបែបគុណវិស័យ និងបរិមាណវិស័យ។

ដើម្បីស្វែងយល់ពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើការធ្វើចំណាកស្រុក ក្រុមអ្នកស្រាវជ្រាវបានប្រើប្រាស់នូវក្របខណ្ឌដែលបានតាក់តែងដោយ Parsons & Nielsen (២០២១); Sigelmann (២០២០); និង Bylander (២០១៦)។ យើងសន្មតថាការធ្វើចំណាកស្រុក បានទទួលរងនូវឥទ្ធិពលដោយប្រយោលពីការប្រែប្រួលអាកាសធាតុតាមរយៈស្ថានភាពជលសាស្ត្រ និងឧតុនិយមដូចជា កំណកអាកាស ឬបរិមាណទឹកដែលមាន ភាពញឹកញាប់នៃទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះ ព្រមទាំងការផ្លាស់ប្តូរនៃកម្ពស់ទឹកភ្លៀង ឬសីតុណ្ហភាព (រូបភាពទី៣)។ ផលប៉ះពាល់អាចត្រូវបានយល់ឃើញតាមស្ថានភាពសេដ្ឋកិច្ចសង្គម និងជីវភាពរស់នៅ ទាក់ទងនឹងការបាត់បង់ទិន្នផលកសិកម្ម ផលប៉ះពាល់នៃប្រាក់ចំណូល ភាពងាយរងគ្រោះ ការបាត់បង់ប្រាក់ឈ្នួល ឬការងារក្នុងតំបន់ និងការធ្លាក់ក្នុងភាពក្រីក្រ ឬបំណុល។ ជនចំណាកស្រុក និងប្រជាជនដែលផ្លាស់ទី ត្រូវបានចាត់ទុកថាជា ក្រុមមនុស្សដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុទាំងនោះ។

រូបភាពទី៣៖ ក្របខណ្ឌស្រាវជ្រាវ




ប្រភព៖ ដកស្រង់ពី Parsons & Nielsen (២០២១); Sigelmann (២០២០); Bylander (២០១៦)

ការធ្វើចំណាកស្រុក គឺជាបាតុភូតដ៏ស្មុគស្មាញមួយដែលបានរងឥទ្ធិពលដោយកត្តាជាច្រើន ដូចជា សេដ្ឋកិច្ច សង្គម បរិស្ថាន គោលនយោបាយ និងប្រជាសាស្ត្រ។ នៅក្នុងផ្នែកនេះយើងនឹងពិភាក្សា អំពីកត្តាដែលប៉ះពាល់ដល់ការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតលើតួនាទីនៃការប្រែប្រួលអាកាសធាតុ។ នៅក្នុងផ្នែកនេះ យើងពិភាក្សាអំពីកត្តាដែលជះឥទ្ធិពលដល់ការធ្វើចំណាកស្រុកនៅកម្ពុជា ដោយផ្តោតលើតួនាទីនៃការប្រែប្រួលអាកាសធាតុ។

កត្តាសេដ្ឋកិច្ច ត្រូវបានលើកឡើងជាញឹកញាប់ថាជាកត្តាជំរុញចម្បងនៃការធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស។ ការធ្វើចំណាកស្រុកអាចត្រូវបានគេមើលឃើញថា ជាយុទ្ធសាស្ត្រចិញ្ចឹមជីវិតដើម្បីទប់ទល់នឹងភាពក្រីក្រ ភាពអត់ការងារធ្វើ ប្រាក់ឈ្នួលទាប ភាពគ្មានដីធ្លី បំណុល និងកង្វះឱកាសនៅតំបន់ជនបទ (Hunsberger et al., ២០១៨; Jacobson et al., ២០១៨; Sigelmann, ២០២០)។ ការធ្វើចំណាកស្រុក ក៏អាចត្រូវបានជំរុញដោយតម្រូវការកម្លាំងពលកម្មនៅក្នុងតំបន់ទីក្រុង តំបន់ឧស្សាហកម្ម និងប្រទេសជិតខាង ជាពិសេសប្រទេសថៃ និងវៀតណាម ដែលជនចំណាកស្រុកអាចទទួលបានប្រាក់ចំណូលខ្ពស់ និងការផ្ញើរប្រាក់ច្រើនជាងក្នុងស្រុក (Hunsberger et al., ២០១៨; Jacobson et al., ២០១៨; Sigelmann, ២០២០)។ ទោះជាយ៉ាងណាក៏ដោយ កត្តាសេដ្ឋកិច្ចតែមួយមុខ មិនអាចពន្យល់បានពេញលេញអំពីលំនាំនៃការធ្វើចំណាកស្រុកទេ ព្រោះជារឿយៗ វាជាប់ពាក់ព័ន្ធជាមួយកត្តាផ្សេងទៀត ដូចជា បណ្តាញសង្គម បទដ្ឋានវប្បធម៌ ចំណូលចិត្តផ្ទាល់ខ្លួន និងលក្ខខណ្ឌបរិស្ថាន (Jacobson et al., ២០១៨; Sigelmann, ២០២០)។ លើសពីនេះទៅទៀត ការធ្វើចំណាកស្រុកមិនតែងតែមានប្រយោជន៍សម្រាប់ជនចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេនោះទេ តែវាក៏អាចនាំមកនូវហានិភ័យ និងភាពខាតបង់ ដូចជា ការកេងប្រវ័ញ្ច ការរំលោភបំពាន ការជួញដូរ ការរើសអើង បញ្ហាសុខភាព និងភាពឯកោក្នុងសង្គមផងដែរ (Hunsberger et al., ២០១៨; Jacobson et al., ២០១៨; Jacobson et al., ២០១៨);(Sigelmann, ២០២០)។

កត្តាសង្គម ក៏ដើរតួនាទីយ៉ាងសំខាន់ ក្នុងការជះឥទ្ធិពលដល់ការសម្រេចចិត្ត និងជាលទ្ធផលនៃការធ្វើចំណាកស្រុក។ បណ្តាញសង្គម ដូចជាចំណងគ្រួសារ ក្រុមញាតិមិត្ត មិត្តភ័ក្តិ និងអ្នកជិតខាង ក៏អាចជួយសម្រួល ឬរារាំងការធ្វើចំណាកស្រុកតាមការផ្តល់ព័ត៌មាន ជំនួយ ការគាំទ្រ និងឥទ្ធិពល (Jacobson et al., ២០១៩; Sigelmann, ២០២០)។ បណ្តាញសង្គមក៏អាចបង្កើតឥទ្ធិពលនៃការធ្វើចំណាកស្រុកតាមខ្សែសង្វាក់ផងដែរ ដែលជនចំណាកស្រុកពីមុនលើកទឹកចិត្ត ឬឧបត្ថម្ភជនចំណាកស្រុកថ្មីឱ្យធ្វើតាមពួកគេ (Jacobson et al., ២០១៨; Sigelmann, ២០២០)។

បទដ្ឋាន និងតម្លៃសង្គមក៏អាចប៉ះពាល់ដល់តរិយាបទចំណាកស្រុកផងដែរ ជាពិសេសទាក់ទងនឹងតួនាទី និងការរំពឹងទុកទាក់ទងនឹងយេនឌ័រ។ នៅក្នុងប្រទេសកម្ពុជាការធ្វើចំណាកស្រុកច្រើនតែមានលក្ខណៈយេនឌ័រ ដោយមានស្ត្រីច្រើនជាងបុរសធ្វើចំណាកស្រុកខាងក្នុងប្រទេស រីឯបុរសច្រើនជាងស្ត្រីធ្វើចំណាកស្រុកជាអន្តរជាតិ (Hunsberger et al., ២០១៨ ; Jacobson et al., ២០១៨; Sigelmann, ២០២០)។ ស្ត្រីមានទំនោរធ្វើចំណាកស្រុក ទៅធ្វើការក្នុងរោងចក្រកាត់ដេរ សេវាកម្មក្នុងស្រុក ឬវិស័យកម្សាន្តនៅក្នុងតំបន់ទីក្រុង ឬប្រទេសជិតខាង ខណៈដែលបុរសមានទំនោរធ្វើចំណាកស្រុក ទៅធ្វើការក្នុងវិស័យសំណង់ កសិកម្ម ឬនេសាទនៅតំបន់ជនបទ ឬប្រទេសជិតខាង (Hunsberger et al., ២០១៨; Jacobson et al., ២០១៨; Sigelmann,២០២០)។ ដូច្នេះការធ្វើចំណាកស្រុកអាចមានផលប៉ះពាល់ផ្សេងៗគ្នាលើស្ត្រី និងបុរសទាក់ទងនឹងការផ្តល់អំណាច ភាពងាយរងគ្រោះ និងសុខុមាលភាព (Hunsberger et al., ២០១៨; Jacobson et al., ២០១៨; Sigelmann, ២០២០)។

កត្តាគោលនយោបាយ ក៏អាចមានឥទ្ធិពលលើការធ្វើចំណាកស្រុកនៅកម្ពុជាផងដែរ។ គោលនយោបាយគុណភាពអភិបាលកិច្ច ការការពារសិទ្ធិមនុស្ស និងនីតិរដ្ឋ អាចប៉ះពាល់ដល់សន្តិសុខ សេរីភាព និងឱកាសរបស់មនុស្សនៅក្នុងតំបន់ដើមកំណើត និងគោលដៅរបស់ពួកគេ (Hunsberger et al., ២០១៨; Sigelmann, ២០២០)។ កត្តាគោលនយោបាយ ក៏អាចបង្កើតក្របខណ្ឌច្បាប់ និងស្ថាប័ន ដែលគ្រប់គ្រងលំហូរចំណាកស្រុក សិទ្ធិ និងសេវាកម្ម (Hunsberger et al., ២០១៨; Sigelmann, ២០២០)។ កត្តាគោលនយោបាយ ក៏អាចមានអន្តរកម្មជាមួយកត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់លទ្ធផលនៃការធ្វើចំណាកស្រុកផងដែរ។ ជាឧទាហរណ៍ កត្តាគោលនយោបាយអាចសម្រុះសម្រួលផល

ប៉ះពាល់នៃកត្តាបរិស្ថាន ដោយការពង្រឹង ឬធ្វើឱ្យចុះខ្សោយនូវភាពធន់ ការបន្សាំខ្លួន និងសមត្ថភាពកាត់បន្ថយរបស់សហគមន៍ និងបុគ្គល (Hunsberger et al., ២០១៨; Sigelmann, ២០២០)។ កត្តាគោលនយោបាយ ក៏អាចធ្វើឱ្យជម្លោះកាន់តែធ្ងន់ធ្ងរឬថមថយ និងភាពតានតឹងដែលអាចកើតឡើងពីដំណើរការចំណាកស្រុក ដូចជា ជម្លោះដីធ្លី ការប៉ះទង្គិចរវាងជនជាតិដើមភាគតិច ឬភាពចលាចលក្នុងសង្គម (Hunsberger et al., ២០១៨; Sigelmann, ២០២០)។

កត្តាប្រជាសាស្ត្រ ក៏ពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីលំនាំនៃការធ្វើចំណាកស្រុកនៅកម្ពុជាផងដែរ។ ទំហំ ប្រជាជន អត្រាកំណើន រចនាសម្ព័ន្ធអាយុ និងការបែងចែកមាត្រដ្ឋាន អាចប៉ះពាល់ដល់ការផ្គត់ផ្គង់និងតម្រូវការនៃកម្លាំងពលកម្ម ធនធាន និងសេវាកម្មនៅក្នុងតំបន់ផ្សេងៗគ្នា (Sigelmann, ២០២០)។ កត្តាប្រជាសាស្ត្រ ក៏អាចឆ្លុះបញ្ចាំងពីឥទ្ធិពលប្រវត្តិសាស្ត្រ និងវប្បធម៌ ដែលកំណត់និន្នាការ និងចំណូលចិត្តការធ្វើចំណាកស្រុកផងដែរ (Sigelmann, ២០២០)។

កត្តាប្រជាសាស្ត្រ ក៏មានឥទ្ធិពលទៅដល់ ផលប៉ះពាល់នៃការធ្វើចំណាកស្រុក និងបញ្ហាប្រឈមផ្សេងៗផងដែរ។ ជាឧទាហរណ៍ ចំនួនប្រជាជនវ័យក្មេង ដែលកំពុងកើនឡើងអាចបង្កើនសក្តានុពលសម្រាប់ការធ្វើចំណាកស្រុក ដែលជាប្រភពនៃពិពិធកម្មប្រាក់ចំណូល និងការចល័តសង្គម (Sigelmann, ២០២០)។ ទោះជាយ៉ាងណាក៏ដោយ ចំនួនប្រជាជនវ័យក្មេងដែលកំពុងកើនឡើង ក៏អាចបង្កបញ្ហាប្រឈមដល់ការអប់រំ សុខភាព ការងារ និងប្រព័ន្ធគាំពារសង្គម ទាំងនៅក្នុងតំបន់ដើម និងតំបន់គោលដៅ (Sigelmann, ២០២០)។

ការសិក្សានេះកំណត់បានអថេរនៃការប្រែប្រួលអាកាសធាតុមួយចំនួនរួមមាន សីតុណ្ហភាព កម្ពស់ទឹកភ្លៀង ព្រឹត្តិការណ៍គ្រោះមហន្តរាយធម្មជាតិ ធនធានទឹក ឧតុនិយម គ្រោះមហន្តរាយ និងព័ត៌មានអាកាសធាតុ និងធាតុអាកាសដែលប្រមូលមកពីក្រសួងពាក់ព័ន្ធ និងមន្ទីរខេត្តផ្សេងៗ។ តាមរយៈអថេរនៃការប្រែប្រួលអាកាសធាតុដែលប្រមូលបាន គម្លាតឬកម្រិតនៃការប្រែប្រួល សីតុណ្ហភាព និងកំណកអាកាស ដែលត្រូវបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវដែលធ្លាប់មានកន្លងមក (Marchiori et al., ២០១១; Parsons, ២០១៥) ត្រូវបានប្រើប្រាស់ ដើម្បីពិនិត្យលើភាពខុសគ្នារវាងតម្លៃមធ្យមក្នុងកម្រិតទសវត្សរ៍ និងតម្លៃមធ្យមរយៈពេលវែងរបស់វានៅតំបន់សិក្សា។ អាំងតង់ស៊ីតេ និងភាពធ្ងន់ធ្ងរនៃគ្រោះមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត នៅក្នុងតំបន់សិក្សាក៏ត្រូវបានបកស្រាយផងដែរ។

បទសម្ភាសន៍ជនបង្គោល (KIIs) ត្រូវបានធ្វើឡើងជាមួយអ្នកពាក់ព័ន្ធ រួមទាំងមន្ត្រីរដ្ឋាភិបាល ជាពិសេស នៅថ្នាក់ក្រោមជាតិ អង្គការក្រៅរដ្ឋាភិបាល និងអ្នកដែលមានចំណេះដឹងផ្សេងទៀត ដើម្បីធ្វើសុពលភាព និងទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបរិបទមូលដ្ឋាន។ ទិន្នន័យបែបគុណវិស័យ ដែលទទួលបានពី KIIs ត្រូវបានចងក្រងយ៉ាងហ្មត់ចត់ និងសង្ខេបភ្លាមៗបន្ទាប់ពីត្រឡប់មកពីទីវាលវិញ។ ទិន្នន័យនិងព័ត៌មាន ដែលប្រមូលបានសម្រាប់តំបន់នីមួយៗត្រូវបានរក្សាទុកក្នុងឯកសារដាច់ដោយឡែកដែលមានលេខកូដ ហើយបន្ទាប់មកចងក្រងទៅតាមប្រភេទ និងលក្ខណៈនៃទិន្នន័យ និងព័ត៌មាន។ តារាងទី២ ខាងក្រោមបង្ហាញពីជនបង្គោលដែលមានសក្តានុពលសំខាន់ៗសម្រាប់ការសម្ភាស KII ។

តារាងទី២៖ សំណាក និងទំហំសំណាក

| ល.រ | វិធីសាស្ត្រប្រមូលទិន្នន័យ | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | បទសម្ភាសន៍ជនបង្គោល (អាជ្ញាធរមូលដ្ឋាននៃខេត្តស្ទឹងត្រែង មណ្ឌលគិរី និងក្រចេះ និងអង្គការមិនមែនរដ្ឋាភិបាលឬអង្គការសហគមន៍មូលដ្ឋាន) | 15 |
| ២ | ការធ្វើអង្កេតជាមួយគ្រួសារដែលមានសមាជិកធ្វើចំណាកស្រុក | 240 |

ការសិក្សានេះ ប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យបឋម ដើម្បីសិក្សាអំពីទំនាក់ទំនងរវាងការប្រែប្រួល អាកាសធាតុ និងការធ្វើចំណាកស្រុក។ ក្រុមអ្នកស្រាវជ្រាវបានប្រមូលទិន្នន័យតាមរយៈ ការស្ទង់មតិលើគ្រួសារ ចំនួន២៤០ ដែលមានសមាជិកចំណាកស្រុក។ កម្រងសំណួរត្រូវបានចងក្រងឡើង និងតេស្តសាកល្បង ដើម្បីពិនិត្យមើលថាតើសំណួរត្រូវនឹងបរិបទក្នុងតំបន់ឬទេ និងដើម្បីមើលថាតើមានចំណុចណាខ្លះ ដែលគួរកែតម្រូវបន្ថែម។ សម្ភាសន៍ត្រូវបានធ្វើឡើងជាមួយនឹងជនចំណាកស្រុក ឬមេគ្រួសារជំនួសជនចំណាកស្រុក ដែលធ្វើចំណាកស្រុកអំឡុងពេលប្រមូលទិន្នន័យ។ កម្រងសំណួរបីប្រភេទត្រូវបានចងក្រងឡើងសម្រាប់ អ្នកឆ្លើយសំណួរក្នុងគ្រួសារ សមាជិកចំណាកស្រុក និងជនបង្គោល (សូមមើលឧបសម្ព័ន្ធនៃកម្រងសំណួរ)។ កម្រងសំណួរបានសួរជាពិសេសអំពី ១) ស្ថានភាពសេដ្ឋកិច្ចសង្គមគ្រួសារ ២) ព័ត៌មាន អំពីសមាជិកគ្រួសារនីមួយៗទាក់ទងនឹងជីវប្រវត្តិរបស់ពួកគេដូចជា អាយុ កម្រិត អប់រំ ស្ថានភាពគ្រួសារ ក៏ដូចជាព័ត៌មានទាក់ទងនឹងការធ្វើចំណាកស្រុក និង ៣) បទពិសោធន៍នៃព្រឹត្តិការណ៍អាកាសធាតុ និងផលប៉ះពាល់លើជីវភាពរបស់ពួកគេ។ ទិន្នន័យដែលទទួលបានពីការអង្កេតត្រូវបានវិភាគតាមរយៈវិធីសាស្ត្រវិភាគ ទិន្នន័យជាក់លាក់មួយចំនួន ដូចជា ការវិភាគទិន្នន័យបែបពិពណ៌នា (តារាងភាគរយ តម្លៃមធ្យម ជាដើម) និងការវិភាគបែបស្ថិតិដូចជា T-test ឬ ANOVA ដើម្បីយល់ដឹងពីទំនាក់ទំនងរវាង ការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក។

វគ្គបណ្តុះបណ្តាលលើកម្រងសំណួរសម្រាប់អ្នកប្រមូលទិន្នន័យចំនួន ១៥នាក់ បានធ្វើឡើង នៅបន្ទប់សន្និសីទនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) កាលពីថ្ងៃទី២៦ ដល់ទី២៧ ខែមិថុនា ឆ្នាំ ២០២៣ បន្ទាប់មកការធ្វើតេស្តសាកល្បងលើកម្រងសំណួរបានដំណើរការនៅថ្ងៃទី២៨ ខែមិថុនា នាពេលព្រឹក នៅភូមិឈើទាលភ្លោះក្រោម ឃុំកញ្ជរ ខេត្តក្រចេះ ខណៈពេលដែលការបញ្ចប់ និងពិនិត្យឡើងវិញនូវកម្រងសំណួរបានធ្វើឡើងនៅពេលរសៀល។ បន្ទាប់ពីបញ្ចប់ការសាកល្បង និងការពិនិត្យឡើងវិញ អ្នកប្រមូលទិន្នន័យចំនួនពីរក្រុម (សមាជិក ៥នាក់ក្នុងមួយក្រុម) បានចេញដំណើរទៅកាន់ ខេត្តស្ទឹងត្រែង និងខេត្តមណ្ឌលគិរី ខណៈដែលមួយក្រុមទៀតស្នាក់នៅក្នុងខេត្តក្រចេះ។ ការអង្កេតតាមគ្រួសារ និងការសម្ភាសន៍ជនបង្គោលជាមួយអ្នកពាក់ព័ន្ធសំខាន់ៗបានចាប់ផ្តើមពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣។ គួរកត់សម្គាល់ថា ថ្ងៃទី១ ខែកក្កដា ជាថ្ងៃដែលយុទ្ធនាការឃោសនាបោះឆ្នោតទូទៅត្រូវបានកំណត់ធ្វើឡើង ហើយអាជ្ញាធរមូលដ្ឋានបានណែនាំមិនឱ្យក្រុមការងារស្រាវជ្រាវចុះធ្វើបទសម្ភាសន៍ឡើយ។ ជាលទ្ធផលក្រុម ការងារប្រមូលបានទិន្នន័យពី ៨០គ្រួសារ នៅក្នុងខេត្តនីមួយៗ និងបានធ្វើបទសម្ភាសន៍ ចំនួន២៤០គ្រួសារ ដែលក្នុងនោះមានសមាជិកចំណាកស្រុកចំនួន ៤៤៤នាក់ នៅក្នុងខេត្តគោលដៅទាំងបី។ នៅក្នុងសំណាក ដែលប្រមូលបាន មានគ្រួសារបីប្រភេទដែលត្រូវបានកំណត់អត្តសញ្ញាណដូចជា គ្រួសារដែលមានស្ត្រីជា មេគ្រួសារ គ្រួសារក្រីក្រ និងគ្រួសារទូទៅ។ ជាសរុប មាន៣២គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ៧០គ្រួសារជាគ្រួសារក្រីក្រ និង ១៣៨គ្រួសារជាគ្រួសារទូទៅ ដែលត្រូវបានសម្ភាសន៍។ ជនចំណាកស្រុកចំនួន ២២៨នាក់ជាបុរស និង ២១៦នាក់ជាស្ត្រី។ យើងបានបញ្ចប់បទសម្ភាសន៍ចំនួន ១៥លើក ជាមួយជនបង្គោល (បុរស ១២នាក់ និងស្ត្រី ២នាក់ រួមមានអាជ្ញាធរឃុំ និងភូមិ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលមួយរូប)(សូមមើលតារាងទី៣ខាងក្រោម)។ ជាចុងក្រោយ សិក្ខាសាលាស្តីពីការផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវថ្នាក់ជាតិ ដែលមានតំណាងភាគីពាក់ព័ន្ធសំខាន់ៗចំនួន ៤៥រូប ដូចជាមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ស្រុក ឃុំ សង្កាត់ អង្គការក្រៅរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកសិក្សា ដៃគូអភិវឌ្ឍន៍ អ្នកបង្កើតគោលនយោបាយ និងអ្នកអនុវត្តបានប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

តារាងទី៣៖ ចំនួនសំណាកតាមឃុំនីមួយៗ

| ខេត្ត | | ឃុំស្រែខ្ទុម | ឃុំក្បាលរមាស | ឃុំកញ្ជរ | សរុប |
|---|---|---|---|---|---|
| គ្រួសារ | ស្ត្រីជាមេគ្រួសារ | 5 | 12 | 15 | 32 |
| | ប័ណ្ណសមធម៌ | 36 | 17 | 17 | 70 |
| | ទូទៅ | 39 | 51 | 48 | 138 |
| សមាជិកចំណាកស្រុក | បុរស | 66 | 71 | 91 | 228 |
| | ស្ត្រី | 79 | 72 | 65 | 216 |
| អាជ្ញាធរមូលដ្ឋាន | បុរស | 6 | 5 | 1 | 12 |
| | ស្ត្រី | 0 | 0 | 2 | 2 |
| អង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់ | បុរស | 1 | 0 | 0 | 1 |
| សរុប | | 232 | 228 | 239 | 699 |

រូបភាពទី៤៖ ផែនទីនៃទីតាំងសិក្សា



# ៤
# លទ្ធផលស្រាវជ្រាវ

នៅផ្នែកនេះ ដោយផ្អែកតាមទិន្នន័យបឋមដែលបានមកពីការសិក្សាទាំងបែបបរិមាណវិស័យ និងគុណវិស័យ យើងផ្តល់ជាលទ្ធផលដូចជា (១) ព័ត៌មានប្រជាសាស្ត្រ សង្គម និងសេដ្ឋកិច្ចអំពីគ្រួសារ និងលក្ខណៈរបស់សមាជិកចំណាកស្រុក (២) និន្នាការអតីតកាល និងបច្ចុប្បន្ននៃគ្រោះថ្នាក់អាកាសធាតុ ដែលប្រជាជនក្នុងតំបន់ជួបប្រទះក្នុងរយៈពេលដប់ឆ្នាំកន្លងមក ការយល់ឃើញរបស់ប្រជាជនទៅលើផលប៉ះពាល់ដ៏ធ្ងន់ធ្ងរទៅលើ ជីវភាពរស់នៅ និង (៣) កត្តាផ្សេងៗជំរុញឱ្យមានការធ្វើចំណាកស្រុក គួបផ្សំនឹងសមត្ថភាពដោះស្រាយរបស់ប្រជាជន។

## ៤.១ លក្ខណៈរបស់អ្នកឆ្លើយតបដែលជាជនចំណាកស្រុក

### *៤.១.១ ប្រវត្តិរូបនៃជនចំណាកស្រុក*

តារាងទី៤ បង្ហាញនូវទិដ្ឋភាពទូទៅនៃទម្រង់ប្រជាសាស្ត្រនៃជនចំណាកស្រុកមកពីកន្លែងសិក្សាចំនួនបីផ្សេងគ្នា គឺ ឃុំកញ្ជរ ក្នុងខេត្តក្រចេះ ឃុំស្រែខ្ទុម ក្នុងខេត្តមណ្ឌលគិរី និងឃុំក្បាលរមាស ក្នុងខេត្តស្ទឹងត្រែង។ តារាងទិន្នន័យត្រូវបានរៀបចំទៅជាផ្នែកជាច្រើនដូចជា ភេទ ទំនាក់ទំនងទៅនឹងមេគ្រួសារ អាយុ និងស្ថានភាពគ្រួសារ។ តារាងនេះបង្កលក្ខណៈងាយស្រួល ដល់ការវិភាគប្រៀបធៀបលើលក្ខណៈចំនួនប្រជាជន និងលំនាំនៃការធ្វើចំណាកស្រុកនៅទូទាំងឃុំទាំងបី ក៏ដូចជាទិន្នន័យសរុបនៃជនចំណាកស្រុកទាំងអស់។ នៅឃុំក្បាលរមាសមានជនចំណាកស្រុកជាបុរសច្រើនជាង (៥៩,១%) ធៀបនឹងជនចំណាកស្រុកជាស្ត្រី (៤០,៩%) ខណៈដែលឃុំកញ្ជរ និងឃុំស្រែខ្ទុម មានជនចំណាកស្រុកជាស្ត្រីប្រមាណ (៥៤,៥% និង ៥១,០%) ច្រើនជាង បើប្រៀបធៀបទៅនឹងបុរស (៤៥,៥% និង ៤០%)។ សរុបមក បុរសមានចំនួនភាគរយច្រើនជាងស្ត្រីបន្តិច (៥១,៤%)។ ជនចំណាកស្រុកភាគច្រើនជាកូនប្រុស ឬកូនស្រីរបស់មេគ្រួសារ (៨០,៧% នៅឃុំកញ្ជរ ៥៣,៨% នៅឃុំស្រែខ្ទុម និង ៥៣,៩% នៅឃុំក្បាលរមាស) ដោយអ្នកដែលចំណាកស្រុកបន្ទាប់គឺជាមេគ្រួសារខ្លួនឯង (៤,៨% ១៦,៦% និង ១៥,៦% រៀងគ្នា) កូនប្រសារប្រុស ឬស្រី (៦,៩% ១៣,៨% និង៨,៣%) និង ប្តីឬប្រពន្ធ (៤,៨% ១៦,៦% និង ១៥,៦% រៀងគ្នា)។ សមាសភាពនៃជនចំណាកស្រុក ដែលមានទំនាក់ទំនងផ្សេងទៀតជាមួយមេគ្រួសារ មានចំនួនតិចតួចប្រមាណ (តិចជាង ៤%)។ ជនចំណាកស្រុកជាមធ្យម មានអាយុប្រហែល ២៥,៧ឆ្នាំ ដែលក្នុងនោះឃុំស្រែខ្ទុមមានជនចំណាកស្រុកដែល មានអាយុជាមធ្យមចំណាស់ជាងគេ (២៧,៨%) និងឃុំកញ្ជរដែលមានជនចំណាកស្រុក ដែលមានអាយុជាមធ្យមក្មេងជាងគេ (២៤,១%)។ អាយុគិតជាមធ្យមនៅពេលធ្វើចំណាកស្រុក គឺប្រហែល២០ឆ្នាំ ដោយឃុំស្រែខ្ទុម មានអាយុច្រើនបំផុតនៅពេលធ្វើចំណាកស្រុក (២៣,៩ឆ្នាំ) និងក្បាលរមាសតិចបំផុត (១៩,១ឆ្នាំ)។ បើក្រឡេកទៅមើលទៅលើស្ថានភាពគ្រួសារ ជនចំណាកស្រុកនៅឃុំកញ្ជរភាគច្រើនជាអ្នកនៅលីវ (៧១,៦%) ខណៈដែលភាគច្រើននៃជនចំណាកស្រុកនៅឃុំពីរផ្សេងទៀតជាអ្នកបានរៀបការរួច (៥៦,៧% នៅឃុំស្រែខ្ទុម និង ៥១,៤% នៅឃុំក្បាលរមាស)។ ប្រភេទស្ថានភាពគ្រួសារដទៃទៀត គឺពុំសូវមានវត្តមាននៅក្នុងចំណោមជនចំណាកស្រុកទេ។ ជនចំណាកស្រុកភាគច្រើន ដែលធ្វើចំណាកស្រុកពេញមួយឆ្នាំ (៤៨,៣% នៅឃុំកញ្ជរ ៥៥,២% នៅឃុំស្រែខ្ទុម និង ៣៥,១% នៅឃុំក្បាលរមាស) បន្ទាប់មកភាគរយច្រើនបន្ទាប់ គឺអ្នកធ្វើចំណាកស្រុកតាមរដូវកាល (៩,៧%, ២៩,៧% និង ៤៣,៥១% រៀងគ្នា) ។ ការធ្វើចំណាកស្រុកអចិន្ត្រៃយ៍មានច្រើន នៅឃុំកញ្ជរ (៣៧,២%) ជាងនៅឃុំស្រែខ្ទុម (១០,៣%) និងក្បាលរមាស (១១,០%)។ ការអមដំណើរជាមួយឪពុកម្តាយមានប្រមាណ ៣,៥% នៅក្នុងឃុំកញ្ជរ ៤,៨% នៅក្នុងឃុំស្រែខ្ទុម និង១០,៤% នៅឃុំក្បាលរមាស និងប្រភេទនៃការធ្វើចំណាកស្រុកផ្សេងទៀតមានប្រមាណ១,៤% នៅក្នុងឃុំកញ្ជរ។

តារាងទី៤៖ ប្រវត្តិរូបនៃសមាជិកគ្រួសារជាជនចំណាកស្រុកតាមឃុំ (គិតជា%)

| ព័ត៌មានប្រជាសាស្ត្រ | ឃុំកញ្ជរ | ឃុំស្រែខ្ទុម | ឃុំក្បាលរមាស | សរុប |
|---|---|---|---|---|
| ភេទ | | | | |
| បុរស | 45.5 | 49.0 | 59.1 | 51.4 |
| ស្ត្រី | 54.5 | 51.0 | 40.9 | 48.7 |
| ទំនាក់ទំនងជាមួយមេគ្រួសារ | | | | |
| មេគ្រួសារ | 4.8 | 16.6 | 15.6 | 12.4 |
| ប្តី ឬប្រពន្ធ | 2.8 | 9.7 | 11.0 | 7.9 |
| បងប្អូនស្រីថ្លៃ ឬបងប្អូនប្រុសថ្លៃ | 0.0 | 3.5 | 2.6 | 2.0 |
| កូនប្រុស ឬកូនស្រី | 80.7 | 53.8 | 53.9 | 62.6 |
| កូនប្រសារប្រុស ឬកូនប្រសារស្រី | 6.9 | 13.8 | 8.4 | 9.7 |
| ចៅ | 3.5 | 2.1 | 5.8 | 3.8 |
| កូនចុង | 1.4 | 0.0 | 0.0 | 0.5 |
| ឪពុកម្តាយ ឬឪពុកម្តាយក្មេក | 0.0 | 0.0 | 1.3 | 0.5 |
| ក្មួយប្រុស ឬក្មួយស្រី | 0.0 | 0.7 | 1.3 | 0.7 |
| អាយុនៃសមាជិកគ្រួសារ ជាជនចំណាកស្រុក | 24.1 | 27.8 | 25.1 | 25.7 |
| អាយុពេលចាប់ផ្តើមធ្វើចំណាកស្រុក | 19.7 | 23.9 | 19.1 | 20.9 |
| ស្ថានភាពគ្រួសារ | | | | |
| រៀបការ | 24.1 | 56.7 | 51.4 | 44.1 |
| នៅលីវ | 71.6 | 35.5 | 42.1 | 49.8 |
| លែងលះ | 0.7 | 2.1 | 4.3 | 2.4 |
| មេម៉ាយ ឬពោះម៉ាយ | 3.6 | 5.7 | 2.1 | 3.8 |

ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

## ៤.១.២ កម្រិតវប្បធម៌

ជនចំណាកស្រុកជាងពាក់កណ្តាល បានធ្វើចំណាកស្រុកពេញមួយឆ្នាំ ហើយខ្លះធ្វើចំណាកស្រុកតាមរដូវកាល និងបាននាំយកកូនតូចៗរបស់ពួកគេតាមខ្លួន។ ស្ត្រីចំណាកស្រុកភាគច្រើន ទំនងជាឈប់រៀននៅថ្នាក់បឋមសិក្សា ខណៈដែលបុរសភាគច្រើនបានបញ្ចប់ថ្នាក់អនុវិទ្យាល័យ។ រូបភាពទី៥ បង្ហាញពីភាពខុសគ្នានៃកម្រិតវប្បធម៌ដោយផ្អែកលើភេទក្នុងចំណោមជនចំណាកស្រុក នៅក្នុងទីតាំងស្រាវជ្រាវ ដោយផ្តល់នូវទិដ្ឋភាពទូទៅនៃកម្រិតអប់រំដែលសម្រេចបាន។ ចាប់ពីកម្រិតបឋមសិក្សា មានចំនួនបុរស(៥១,២%) ច្រើនជាងស្ត្រី (៤៤,៩៣%)។

ផ្ទុយទៅវិញ នៅកម្រិតសិក្សាថ្នាក់អនុវិទ្យាល័យ ចំនួនស្ត្រីមានកាន់តែច្រើន (៣៤,៣%) បើប្រៀបធៀបទៅនឹងបុរស (២៣%)។ ចំពោះការអប់រំនៅថ្នាក់វិទ្យាល័យ និងកម្រិតឧត្តមសិក្សា ស្ត្រីមានអត្រាតិចជាងបុរស ១២,៦% និង ២,៤% រៀងគ្នា ចំណែកឯបុរសមានអត្រា ១៥,០% និង៤,២% រៀងគ្នា ដែលនេះបានគូសបង្ហាញពីឧបសគ្គសក្តានុពល ឬឱកាសដែលនៅមានកម្រិត សម្រាប់ស្ត្រីក្នុងទទួលបានការអប់រំកម្រិតខ្ពស់។ ជាងនេះទៅទៀត អត្រាអនក្ខរភាពក្នុងចំណោមបុរស និងស្ត្រីគឺមានភាពប្រហាក់ប្រហែលគ្នា (៦,៦% និង ៥,៨% រៀងគ្នា)។

រូបភាពទី៥៖ កម្រិតវប្បធម៌តាមភេទ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

### ៤.១.៣ ប្រភេទនៃការធ្វើចំណាកស្រុក

ជនចំណាកស្រុកភាគច្រើនបានរៀបការហើយ ឬនៅលីវ ជាកូនប្រុស ឬកូនស្រីក្នុងគ្រួសារ។ ចំនួនបុរស និងស្ត្រីដែលនៅក្នុងទីតាំងសិក្សាគោលដៅមានសមាមាត្រនឹងគ្នា នៅពេលពួកគេធ្វើការផ្លាស់ទីចេញដើម្បីស្វែងរកការងារ ដោយចំណុចនេះបានបង្ហាញពីតួនាទីសំខាន់របស់យុវនារីដែលមានអាយុ ២៤ឆ្នាំជាមធ្យម ក្នុងការទទួលបានឱកាសការងារ ហើយពួកគេទាំងនេះទំនងជាមិនសូវពឹងផ្អែកលើការងារដែលមិនមានប្រាក់ខែ ឬស្នាក់នៅតែផ្ទះ។ នៅក្នុងប្រទេសកម្ពុជា កូនៗតែងជួយឪពុកម្តាយ ដោយការរកប្រាក់ចំណូល ដែលទូទៅជាវប្បធម៌ហើយក៏ជាទំនួលខុសត្រូវធំមួយដែលត្រូវធ្វើដើម្បីគ្រួសារ។

ក្នុងរូបភាពទី៦ បង្ហាញពីលំនាំនៃការធ្វើចំណាកស្រុកដោយមានការបែងចែកតាមភេទ។ ការវិភាគបង្ហាញឱ្យឃើញថា លំនាំនៃការធ្វើចំណាកស្រុកដែលលេចធ្លោ ដោយមិនគិតពីភេទ គឺទាក់ទងទៅនឹងការស្វែងរកឱកាសការងារពេញមួយឆ្នាំ។ ចំពោះការធ្វើចំណាកស្រុកតាមរដូវកាល ជនចំណាកស្រុកជាបុរសមានភាគរយខ្ពស់ (៣១,១%) បើធៀបទៅនឹងជនចំណាកស្រុកដែលជាស្ត្រី (២៤,៥%)។ ការធ្វើចំណាកស្រុកជាអចិន្ត្រៃយ៍ ដែលជាបាតុភូតគួរឱ្យកត់សម្គាល់នៅក្នុងតំបន់សិក្សា ដែលបង្ហាញពីនិន្នាការពិសេសមួយដែលសមាមាត្រស្ត្រី (២០,៤%) មានភាគរយធំជាងបន្តិចបើប្រៀបធៀបទៅនឹងបុរស (១៨,៤%)។ គួរកត់សម្គាល់ដែរថា ភាគរយនៃស្ត្រីដែលធ្វើចំណាកស្រុកដើម្បីអមដំណើរឪពុកម្តាយរបស់ពួកគេមាន (៨,៣%) ច្រើនជាង ភាគរយនៃបុរស (៤,៤%) ដែលធ្វើចំណាកស្រុកក្នុងគោលបំណងដូចគ្នា។

រូបភាពទី៦៖ ប្រភេទនៃចំណាកស្រុកតាមភេទ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

### *៤.១.៤ ប្រភេទការងារ និងគោលដៅចំណាកស្រុក*

ជនចំណាកស្រុកទាំងជាបុរស និងស្ត្រីមានលទ្ធភាពទទួលបានការងារសម្បូរបែប អាស្រ័យលើបទពិសោធន៍ ជំនាញ ការអប់រំ និងតាមរយៈបណ្តាញ។ រូបភាពទី៧ បង្ហាញពីលំនាំការងារ គួរឱ្យកត់សម្គាល់មួយ ដែលត្រូវបានសង្កេតឃើញនៅក្នុងចំនួនប្រជាជនចំណាកស្រុក ដែលកំណត់ដោយការបែងចែកតាមភេទ។ ព័ត៌មាននេះបង្ហាញថា ការងារចម្បងនៃប្រជាជនបុរសមួយភាគធំគឺកម្មករស៊ីឈ្នួលម្តងម្កាល ដែលធ្វើការងារពិបាក និងគ្រោះថ្នាក់ ជាពិសេសនៅក្នុងវិស័យដែលទាក់ទងនឹងការសាងសង់ និងការផ្សារដែក ដែលស្មើនឹង ២៤,៧%។ លើសពីនេះ និន្នាការគួរឱ្យចាប់អារម្មណ៍មួយបានលេចឡើង ដែលក្នុងនោះស្ត្រីជាជនចំណាកស្រុកដែលមានការងារជាបុគ្គលិកក្រុមហ៊ុន មានចំនួនច្រើនជាងបុរស ក្នុងអត្រា ១៧,៣%។ ជនចំណាកស្រុកក៏ប្រកបរបរផ្សេងៗផងដែរ ទោះបីក្នុងកម្រិតតិចតួចក៏ដោយ ដែលក្នុងនោះរួមមាន តួនាទីដូចជា កម្មករផ្នែកវាយនភណ្ឌកាត់ដេរ ពលករបំរើការងារនៅតាមផ្ទះ និងអ្នករាជការជាដើម។

តំណាងអង្គការមិនមែនរដ្ឋាភិបាលមួយរូប បានលើកឡើងថា ជនចំណាកស្រុកមួយចំនួនបានទៅធ្វើការនៅឃុំពូជ្រៃ ស្រុកពេជ្រាដា (ខេត្តមណ្ឌលគិរី) បែបជាការងារពេញម៉ោងនៅចម្ការម្រេចរបស់ក្រុមហ៊ុនឯកជនកូរ៉េ ក្រុមហ៊ុនរុករករ៉ែមាស ឬនៅចម្ការកៅស៊ូផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនឯកជនបារាំង។ ជនចំណាកស្រុកខ្លះធ្វើចំណាកស្រុកក្នុងរយៈពេលខ្លី ក្នុងរដូវមិនប្រមូលផលដំណាំ ដើម្បីធ្វើការងារសំណង់ [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយអ្នកសម្របសម្រួលកម្មវិធី អង្គការភូមិខ្ញុំ ខេត្តមណ្ឌលគិរី ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣]។ អ្នកភូមិក្បាលរមាសខ្លះធ្វើចំណាកស្រុកតាមរដូវ ដើម្បីរកការងារធ្វើជាពលករនៅតាមកសិដ្ឋានពាណិជ្ជកម្ម ឬក្រុមហ៊ុនឯកជន ដែលមានទីតាំងនៅជិតភូមិក្នុងឃុំ។ ក្រុមហ៊ុនមួយមានឈ្មោះថាឡាយ តែងតែប្រមូលផលប្រេងដូង ចេក ស្វាយចន្ទី និងកៅស៊ូ [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយមេភូមិក្បាលរមាស ខេត្តស្ទឹងត្រែង ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣]។ ការងារកាន់តែច្រើនមាននៅក្នុងតំបន់ទីក្រុង ពីព្រោះអ្នកស្រុកមិនទទួលយកការងារដែលមានគ្រោះថ្នាក់ ហើយជាទូទៅចូលរួមជាភាគច្រើននៅក្នុងឧស្សាហកម្មផ្តល់សេវា។

ខណៈពេលដែលមានឱកាសការងារក្នុងស្រុកច្រើនដែលទាំងបុរស និងស្ត្រី អាចទៅធ្វើការនៅទីរួមខេត្ត រាជធានីភ្នំពេញ ទីក្រុងធំៗមួយចំនួន និងតំបន់សេដ្ឋកិច្ចពិសេស ដូចជា ក្រុងព្រះសីហនុ និងក្រុងបាវិតជាដើម អ្នកស្រុកមួយចំនួនតូចអាចទទួលបានការងារនៅក្រៅប្រទេសផងដែរ។ អ្នកភូមិភាគច្រើនយល់ថា ការធ្វើចំណាកស្រុកតម្រូវឱ្យមានចំណាយខ្ពស់ ហើយពួកគាត់ពុំមានលទ្ធភាពរាប់រងក្នុងការធ្វើដំណើរទៅក្រៅប្រទេសដើម្បីរកការងារធ្វើ ឬទទួលបានព័ត៌មានមិនគ្រប់គ្រាន់ដើម្បីចាប់យកឱកាសនោះ។

រូបភាពទី៧៖ ប្រភេទការងារតាមភេទ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

រូបភាពទី៨៖ គោលដៅនៃការធ្វើចំណាកស្រុកតាមភេទ (គិតជា%)




ប្រភព: អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

រូបភាពទី៨ បង្ហាញពីរបាយប្រជាជនជាបុរស និងស្ត្រីនៅក្នុងតំបន់សិក្សា ដែលបានធ្វើការចំណាកស្រុកទៅតាមទីតាំងគោលដៅផ្សេងៗ។ ការធ្វើចំណាកស្រុកនៅក្នុង និងក្រៅខេត្តក៏ដូចជាការធ្វើចំណាកស្រុកទៅកាន់ តំបន់ទីក្រុងគឺជាលំនាំទូទៅក្នុងចំណោមជនចំណាកស្រុកទាំងពីរភេទ។ ស្ត្រីមានទំនោរទៅលើ ការធ្វើចំណាកស្រុកទៅកាន់ទីក្រុង (៤៦,៤%) ច្រើនជាងបុរស (៣០,៥%)។ ផ្ទុយទៅវិញ បុរស (៤៥,៣%) បង្ហាញទំនោរទៅលើការធ្វើចំណាកស្រុកនៅក្នុង និងក្រៅខេត្តច្រើនជាង បើធៀបនឹងស្ត្រី (៣៥,០%)។ សមាមាត្រនៃជនចំណាកស្រុកប្រុស និងស្រី ដែលប្រកបការងារក្រៅឃុំ និងក្រៅប្រទេស មានតិចតួច និងប្រហាក់ប្រហែលគ្នា។ ជនចំណាកស្រុកទំនងជាទៅធ្វើការជាបុគ្គល ហើយ

កម្រនឹងទៅជាក្រុមគ្រួសារដើម្បីស្វែងរកការងារធ្វើនៅក្នុងទីក្រុង។ ក្រៅពីនេះ គេក៏សង្កេតឃើញមានជនអន្តោប្រវេសន៍ចូលមកឃុំដើម្បីធ្វើការនៅចម្ការដំឡូងមី ឬការងារពលកម្មក្នុងវិស័យកសិកម្ម [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយក្រុមប្រឹក្សាឃុំកញ្ជរ ខេត្តក្រចេះ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣]។ ខណៈពេលដែលជនចំណាកស្រុកភាគច្រើនធ្វើការនៅរោងចក្រ ដូចជាឧស្សាហកម្មកាត់ដេរ និងសំណង់នៅក្នុងទីក្រុងភ្នំពេញ និងកំពង់សោម ជនចំណាកស្រុកមួយចំនួនក៏ចូលចិត្តធ្វើការនៅក្រៅប្រទេសផងដែរ ដូចជា ទៅប្រទេសជប៉ុន ឬកូរ៉េខាងត្បូង [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយមេភូមិព្រែកចំឡាក់ ឃុំកញ្ជរ ខេត្តក្រចេះ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣]។

### *៤.១.៥ ប្រាក់ចំណូលនៅតាមគោលដៅចំណាកស្រុកនីមួយៗ*

ការងារនៅក្រៅប្រទេស ផ្តល់ប្រាក់ចំណូលខ្ពស់ជាងការងារក្នុងប្រទេស និងខ្ពស់ជាងនៅក្នុងស្រុក។ ទោះបីជាស្ត្រីចំណាកស្រុកមួយចំនួន បម្រើការនៅក្រុមហ៊ុនឯកជន រដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល ប្រាក់ចំណូលជាមធ្យមដែលស្ត្រីរកបាន គឺទាបជាងបុរស នៅក្នុងគ្រប់ប្រភេទនៃគោលដៅចំណាកស្រុក លើកលែងតែការងារតាមខេត្ត។

តារាងទី៥ បង្ហាញពីទិដ្ឋភាពទូទៅនៃប្រាក់ចំណូលប្រចាំខែជាមធ្យមរបស់ជនចំណាកស្រុក ដោយផ្អែកលើភេទរបស់ពួកគេ និងទីកន្លែងដែលពួកគេបានធ្វើចំណាកស្រុកទៅធ្វើការ។ ក្នុងន័យទូទៅ ជនចំណាកស្រុក ជាបុរសភាគច្រើនទទួលបានប្រាក់ចំណូលខ្ពស់ជាង បើប្រៀបធៀបទៅនឹងស្ត្រី។ ទិន្នន័យបង្ហាញថាប្រាក់ ចំណូលប្រចាំខែជាមធ្យមរបស់បុរសគឺ ២១៨,១៣ដុល្លារអាមេរិក ខណៈដែលស្ត្រីទទួលបាន ១៨៥,៨៥ដុល្លារអាមេរិក ដែលទាបជាងបុរសបន្តិច។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលរបស់ស្ត្រី គឺទាបជាងប្រាក់ឈ្នួលអប្បបរមាឆ្នាំ ២០២៣ (២០០ដុល្លារអាមេរិកក្នុងមួយខែ) ដែលកំណត់ដោយរដ្ឋាភិបាល។

នៅពេលពិនិត្យអំពី ឥទ្ធិពលដែលគោលដៅចំណាកស្រុកមានលើប្រាក់ចំណូល វាបានក្លាយជាភស្តុតាងមួយដែលបង្ហាញថា ការធ្វើចំណាកស្រុកទៅក្រៅប្រទេស ផ្តល់នូវសក្តានុពលក្នុងការរកប្រាក់ចំណូលកាន់តែច្រើន។ ជនចំណាកស្រុកជាបុរស ដែលបានជ្រើសរើសគោលដៅទៅក្រៅប្រទេស បានរាយការណ៍ពីប្រាក់ចំណូលប្រចាំខែជាមធ្យមចំនួន ៦១១,២៥ដុល្លារអាមេរិក ចំណែកស្ត្រីចំណាកស្រុកទៅក្រៅប្រទេសដូចគ្នា រកបានប្រហែល ២៩៤,១០ដុល្លារអាមេរិក ក្នុងមួយខែ។ ដោយផ្តោតលើជនចំណាកស្រុក នៅក្នុងតំបន់ទីក្រុង និងមិនគិតពីភេទ តាមរយៈទិន្នន័យបានបង្ហាញថា ពួកគេអាចរំពឹងថានឹងទទួលបានប្រាក់ចំណូលស្រដៀងគ្នា ដែលជាមធ្យមប្រហែល ២០០ដុល្លារ អាមេរិកក្នុងមួយខែ។ នេះបង្ហាញឱ្យឃើញថា ការធ្វើចំណាកស្រុកទៅកាន់ទីក្រុងមិនសុទ្ធតែនាំឱ្យមានគម្លាតនៃ ប្រាក់ចំណូលទៅតាមភេទនោះទេ។

តារាងទី៥៖ ប្រាក់ចំណូលសរុបតាមគោលដៅចំណាកស្រុក និងភេទ (គិតជាដុល្លារក្នុងមួយខែ)

| គោលដៅចំណាកស្រុក | បុរស | ស្ត្រី | សរុប |
|---|---|---|---|
| ខាងក្រៅឃុំ/ស្រុក | 132.63 | 69.24 | 101.19 |
| ក្នុង/ក្រៅខេត្ត | 178.52 | 184.85 | 181.32 |
| ទីក្រុង | 201.13 | 197.40 | 198.92 |
| បរទេស | 611.25 | 294.10 | 484.39 |
| សរុបចំណូលជាមធ្យម | 218.13 | 185.85 | 202.32 |

ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

ផ្ទុយទៅវិញ បើប្រៀបធៀបជនចំណាកស្រុកដែលធ្វើការនៅក្នុងស្រុកដូចគ្នា និងភូមិកន្លែងកំណើតដើមរបស់ពួកគេ មានទំនោររកប្រាក់ចំណូលបានទាបជាងនេះ។ សម្រាប់បុរស នេះមានន័យថា ទទួលបានប្រាក់ខែជាមធ្យមប្រហែល ១៣២ដុល្លារអាមេរិកក្នុងមួយខែ ខណៈដែលស្ត្រីក្នុងលក្ខខណ្ឌស្រដៀងគ្នារកបានប្រហែល ៦៩ដុល្លារអាមេរិកក្នុងមួយខែ។

### ៤.១.៦ បណ្ដាញនៃការងារចំណាកស្រុក

ទំនាក់ទំនងសង្គមដើរតួនាទីយ៉ាងសំខាន់នៅក្នុងការស្វែងរកការងារចំណាកស្រុក ដែលធ្វើឡើងដោយតាមរយៈមិត្តភក្តិ អ្នកជិតខាង និងសាច់ញាតិ។ វាកើតឡើងនៅពេលដែលមនុស្សធ្វើចំណាកស្រុក ដើម្បីស្វែងរកឱកាសការងារនៅក្នុងទីក្រុង ឬទីក្រុងនៃប្រទេសជិតខាងដូចជាប្រទេសថៃ ខណៈដែលដំណើរការផ្លូវការនៅមានតិចតួចនៅឡើយ។

រូបភាពទី៩ បង្ហាញពីរបៀបនៃការរកការងារធ្វើរវាងបុរស និងស្ត្រី ដែលបានប្រើវិធីសាស្ត្រផ្សេងគ្នាដើម្បីទទួលបានការងារ។ មនុស្សភាគច្រើនដែលបានចូលរួមក្នុងការសិក្សានេះ បានពឹងផ្អែកលើទំនាក់ទំនងសង្គមរបស់ពួកគេ ដូចជាមិត្តភក្តិ អ្នកជិតខាង និងសាច់ញាតិ ដើម្បីស្វែងរកឱកាសការងារ។ វិធីសាស្ត្រទីពីរដែលពេញនិយមបំផុត គឺពាក់ព័ន្ធនឹងការទាក់ទងដោយផ្ទាល់ទៅកាន់និយោជក ឬក្រុមហ៊ុន តាមរយៈការតាមដានយ៉ាងជិតស្និទ្ធនៅលើប្រព័ន្ធអនឡាញ។ ការប្រើប្រាស់ភ្នាក់ងាររកការងារស្របច្បាប់ ឬខុសច្បាប់ និងមធ្យោបាយផ្សេងទៀត ប្រៀបធៀបទៅនឹងមធ្យោបាយខាងលើ គឺមានចំនួនតិចតួចបំផុត។ រូបភាពនេះក៏បង្ហាញពីភាពខុសគ្នាដ៏គួរឱ្យចាប់អារម្មណ៍រវាងបុរស និងស្ត្រីផងដែរ។ ជាឧទាហរណ៍ ស្ត្រីមានទំនោរពឹងផ្អែកលើសាច់ញាត្តិ និងមិត្តភ័ក្តិ កាន់តែច្រើន ខណៈដែលបុរសចូលចិត្តប្រើប្រាស់សេវាកម្មអនឡាញ និងទំនាក់ទំនងដោយផ្ទាល់ជាមួយនិយោជក ឬក្រុមហ៊ុន។

រូបភាពទី៩៖ បណ្ដាញការងារចំណាកស្រុកតាមយេនឌ័រ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

## ៤.២ ភាពប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ

ផ្នែកខាងក្រោម ពិពណ៌នាអំពីកម្រិតនៃភាពប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ផលប៉ះពាល់ដែលប្រជាជនក្នុងតំបន់បានទទួលរងក្នុងរយៈពេលដប់ឆ្នាំកន្លងមក និងយុទ្ធសាស្ត្រឆ្លើយតបផ្សេងៗគ្នា នៅក្នុងទីតាំងសិក្សាស្រាវជ្រាវ។

### ៤.២.១ ប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ

ភាពងាយរងគ្រោះទាប ឬខ្ពស់នៅក្នុងឃុំ អាស្រ័យទៅលើកម្រិតនៃភាពប្រឈម និងសមត្ថភាពបន្សាំរបស់ប្រជាជនដែលប្រឈមមុខនឹងគ្រោះថ្នាក់អាកាសធាតុ។ ឃុំដែលនៅតំបន់ផ្សេងៗគ្នាត្រូវបានប្រឈម និងរងផលប៉ះពាល់ខុសៗគ្នាទៅតាមប្រភេទនៃការគំរាមកំហែងដោយបរិស្ថាន។

រូបភាពទី១០ បង្ហាញពីផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិផ្សេងៗ លើប្រជាជន ដែលរស់នៅក្នុងតំបន់ផ្សេងៗគ្នា។ ជារួមមក ប្រជាជនមកពីគ្រប់តំបន់ទាំងអស់ដែលបានចូលរួម ក្នុងការសិក្សានេះបានជួបប្រទះនូវ មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុជាច្រើន រួមទាំងការកើនឡើងកម្តៅ ទឹកជំនន់ ភាពរាំងស្ងួត និងផ្សេងៗទៀតក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ទោះជាយ៉ាងណាក្តី តំបន់នីមួយៗ ប្រឈមនឹងបញ្ហាដោយឡែកៗ និងភាពងាយរងគ្រោះផ្សេងៗពីគ្នា ដោយសារលក្ខណៈភូមិសាស្ត្រ និងកត្តាពាក់ព័ន្ធ។ ជាឧទាហរណ៍ នៅក្នុងឃុំកញ្ជរ មានការប្រឈមមុខខ្លាំងនឹងភាពងាយរងគ្រោះភាពរាំងស្ងួត (៦៧,១%) ទឹកជំនន់ (៦៥,៨%) និងការផ្ទុះរីករាលដាលនៃសត្វល្អិត (៥១,៣%) ប៉ុន្តែធ្លាប់មានបទពិសោធន៍រងគ្រោះទាបទៅនឹងភ្លើងឆេះព្រៃ (៨,៨%)។ ផ្ទុយទៅវិញ ឃុំស្រែខ្ទុមទទួលរងនូវអាកាសធាតុក្តៅខ្លាំង (៩៧,៥%) ខ្យល់ព្យុះ (៨១,៣%) ការផ្លាស់ប្តូររដូវ (៧២,៥%) និង ភាពរាំងស្ងួត (៥៨,៣%) តែមានភាពងាយរងគ្រោះទាបចំពោះទឹកជំនន់ (៤២,៣%) និងភ្លើងឆេះព្រៃ (២៧,៥%)។ អ្នកភូមិនៅឃុំក្បាលរមាស សង្កេតឃើញមានកើតមានញឹកញាប់នូវ ខ្យល់ព្យុះ (៩៨,៨%) សីតុណ្ហភាពខ្ពស់ (៩៥,០%) ការផ្លាស់ប្តូររដូវ (៨០,០%) និងភ្លើងឆេះព្រៃ (៧៥,០%) គ្រោះរាំងស្ងួត (៦៦,៣%) និងការផ្ទុះរីករាលដាលនៃសត្វល្អិត (៥១,៣%) ខណៈដែលអត្រាទឹកជំនន់មានកម្រិតទាប (២២,៨ %)។

រូបភាពទី១០៖ ប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុដែលអ្នកស្រុកបានជួបប្រទះក្នុងរយៈពេលដប់ឆ្នាំកន្លងមក តាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

### ៤.២.២ ការយល់ឃើញរបស់ប្រជាពលរដ្ឋក្នុងតំបន់ ចំពោះការខូចផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ

តារាងទី៦ បង្ហាញពីការវិភាគអំពីរបៀបដែលតំបន់ផ្សេងៗ បានរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ ហើយតេស្ត ANOVA ត្រូវបានប្រើប្រាស់ដើម្បីស្វែងយល់អំពីភាពខុសគ្នានៃឃុំសិក្សាទាំងបី។ មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុចំនួនប្រាំពីរប្រភេទ ត្រូវបានបង្ហាញនៅក្នុងតារាងរួមមាន៖ កម្តៅ ឬសីតុណ្ហភាពខ្ពស់ ទឹកជំនន់ ភាពរាំងស្ងួត ការផ្លាស់ប្តូររដូវ ខ្យល់ព្យុះ ការផ្ទុះរាលដាលសត្វល្អិត និងភ្លើងឆេះព្រៃ។ ក្នុងតារាងក៏បានបង្ហាញអំពីកម្រិតនៃផលប៉ះពាល់បណ្តាលពីមុខសញ្ញាគ្រោះថ្នាក់ទាំងនេះ ដែលការវាយតម្លៃជារួមបង្ហាញពីកម្រិតនៃផលប៉ះពាល់មានលំដាប់ចាប់ពី "ទាបខ្លាំង" "ទាប" និង "មធ្យម"។ "សីតុណ្ហភាពខ្ពស់" និង "ខ្យល់ព្យុះ" ត្រូវបានបង្ហាញថាជា មុខសញ្ញាគ្រោះថ្នាក់ដែលស្ថិតនៅកម្រិតនៃផលប៉ះពាល់ "មធ្យម" ប៉ុន្តែមានកម្រិតធ្ងន់ធ្ងរជាងគេ ក្នុងចំណោមមុខសញ្ញាគ្រោះថ្នាក់ផ្សេងទៀត។ "គ្រោះ

រាំងស្ងួត" និង "ការផ្ទុះរីករាលដាលនៃសត្វល្អិត" ជាមុខសញ្ញាគ្រោះថ្នាក់ ដែលមានផលប៉ះពាល់ទាប ដែលស្ថិតនៅក្នុងកម្រិតធ្ងន់ធ្ងរតិចជាងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត។ ការវិភាគស្ថិតិអំពីភាពរាំងស្ងួត និងការផ្លាស់ប្តូរកម្ពស់ទឹកភ្លៀង មានសារៈសំខាន់ជាអត្ថន័យ ខណៈដែលការផ្ទុះរីករាលដាលសត្វល្អិតមិនមានសារៈសំខាន់ជាអត្ថន័យទេ។ ជាចុងក្រោយបង្អស់ "ភ្លើងឆេះព្រៃ" ដែលស្ថិតនៅក្នុងភាពធ្ងន់ធ្ងរកម្រិត "ទាបខ្លាំង" មានសារៈសំខាន់ជាអត្ថន័យ។

តារាងទី៦៖ កម្រិតនៃផលប៉ះពាល់ដោយមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដែលអ្នកក្នុងតំបន់យល់ឃើញ (គិតជា%)

| មុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ | ឃុំកញ្ជរ (N=80) | | ឃុំស្រែខ្ទុម (N=80) | | ឃុំក្បាលរមាស (N=80) | | សរុប (N=240) | |
|---|---|---|---|---|---|---|---|---|
| | WAI | OA | WAI | OA | WAI | OA | WAI | OA |
| សីតុណ្ហភាពខ្ពស់ | 0.45 | មធ្យម | 0.63 | ខ្ពស់ | 0.63 | ខ្ពស់ | 0.57*** | មធ្យម |
| ទឹកជំនន់ | 0.32 | ទាប | 0.21 | ទាប | 0.16 | ទាបខ្លាំង | 0.23*** | ទាបខ្លាំង |
| គ្រោះរាំងស្ងួត | 0.33 | ទាប | 0.30 | ទាប | 0.42 | មធ្យម | 0.35** | ទាប |
| ការប្រែប្រួលរដូវ | 0.29 | ទាប | 0.41 | មធ្យម | 0.45 | មធ្យម | 0.38*** | ទាប |
| ខ្យល់ព្យុះ | 0.35 | ទាប | 0.41 | មធ្យម | 0.74 | ខ្ពស់ | 0.50*** | មធ្យម |
| ការផ្ទុះរីករាលដាលនៃសត្វល្អិត | 0.27 | ទាបខ្លាំង | 0.30 | ទាប | 0.36 | ទាប | 0.31 | ទាប |
| ភ្លើងឆេះព្រៃ | 0.03 | ទាបខ្លាំង | 0.12 | ទាបខ្លាំង | 0.45 | មធ្យម | 0.20*** | ទាបខ្លាំង |

ចំណាំ៖ WAI (weight average index) បង្ហាញពីសន្ទស្សន៍មធ្យមទម្ងន់ ដែលបានវាស់វែងនៅលើមាត្រដ្ឋាន ដែលមាន ៥កម្រិត (ទាបខ្លាំង = ០,០០-០,២០ ទាប = ០,២១-០,៤០ មធ្យម = ០,៤១-០,៦០ ខ្ពស់ = ០,៦១-០,៨០ និងខ្ពស់បំផុត = ០,៨១-១,០០)។ OA (overall assessment) បង្ហាញពីការវាយតម្លៃជារួម។ សញ្ញាផ្កាយ (*, **, និង ***) បញ្ជាក់អំពីភាពខុសគ្នាដាច់បែបស្ថិតិ នៅកម្រិត ០,១ ០,០៥ និង ០,០១ ជាលំដាប់រៀងគ្នា។

ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ ២០២៣

ការឆ្លើយតបក្នុងការស្ទង់មតិពីប្រជាជនអំពីកម្តៅ ឬសីតុណ្ហភាពខ្ពស់ នៅឃុំកញ្ជរភាគច្រើនរាយការណ៍ថា ស្ថិតនៅក្នុងកម្រិតផលប៉ះពាល់ "មធ្យម" (WAI=០,៤៥)។ តែផ្ទុយទៅវិញ ប្រជាជននៅឃុំស្រែខ្ទុម និងឃុំក្បាលរមាស មានភាពងាយរងគ្រោះចំពោះកម្តៅខ្ពស់ជាង ដោយសារពួកគេបានឆ្លើយតបក្នុងការស្ទង់មតិភាគច្រើន ក្នុងកម្រិត "ខ្ពស់" (WAI=០,៦៣ និង WAI=០,៦៤រៀងគ្នា)។ ការឆ្លើយតបក្នុងការស្ទង់មតិអំពីទឹកជំនន់ នៅឃុំកញ្ជរ និងឃុំស្រែខ្ទុម មានភាពស្រដៀងគ្នា នៅក្នុងកម្រិត "ទាប" (WAI=០,៣២ និង WAI=០,២១ រៀងគ្នា)។ ខណៈដែលឃុំក្បាលរមាសមិនសូវងាយរងគ្រោះ ដោយសារទឹកជំនន់ យោងលើសមាមាត្រទាបនៃការឆ្លើយតបក្នុងការស្ទង់មតិមានកម្រិត "ទាបខ្លាំង" (WAI=០,១៦)។ នៅឃុំកញ្ជរ និងឃុំស្រែខ្ទុម មិនសូវត្រូវបានគេជួបប្រទះនឹងបញ្ហាភាពរាំងស្ងួត ដោយលទ្ធផលបង្ហាញនៅកម្រិត "ទាប" (WAI=០,៣៣ និង WAI=០,៣០ រៀងគ្នា) ខណៈឃុំក្បាលរមាស រងផលប៉ះពាល់ខ្លាំងជាង ដោយស្ថិតនៅកម្រិត "មធ្យម" (WAI=០,៤២)។ ប្រជាជនក្នុងឃុំកញ្ជរក្នុងការស្ទង់មតិអំពីការប្រែប្រួលរដូវ នៅតែមានអ្នកឆ្លើយតបថារងគ្រោះនៅកម្រិត "ទាប" (WAI=០,២៩) ខណៈពេលដែលឃុំស្រែខ្ទុម និងឃុំក្បាលរមាសមានការឆ្លើយតបច្រើនក្នុងកម្រិត "មធ្យម" (WAI=០,៤១ និង WAI=០,៤៥ រៀងគ្នា)។ ប្រជាជនក្នុងឃុំកញ្ជរមួយផ្នែកធំក្នុងការស្ទង់មតិអំពីខ្យល់ព្យុះ បានឆ្លើយតបថាបានរងគ្រោះក្នុងកម្រិត "ទាប" (WAI=០,៣៥) ខណៈដែល ឃុំស្រែខ្ទុមមានការឆ្លើយតបច្រើនជាងដែលថាបានរងគ្រោះនៅកម្រិត "មធ្យម" (WAI=០,៤១)។ ឃុំក្បាលរមាសមានចំនួនការឆ្លើយតបគួរឱ្យកត់សម្គាល់

នៅកម្រិត "ខ្ពស់" (WAI=0,៧៤) ចំពោះខ្យល់ព្យុះ។ ឃុំកញ្ជរមិនសូវងាយនឹងជួបប្រទះនូវការរាតត្បាតរបស់សត្វល្អិត ប្រៀបធៀបនឹងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត ដោយបានបង្ហាញលទ្ធផលក្នុងកម្រិត "ទាបខ្លាំង" (WAI=0,២៧)។ ខណៈដែលឃុំស្រែខ្ទុម និងឃុំក្បាលរមាសមានផលប៉ះពាល់ខ្លាំងជាងដោយស្ថិតនៅក្នុងកម្រិត "ទាប" (WAI=0,៣0 និង WAI=0,៣៦ រៀងគ្នា)។ ឃុំស្រែខ្ទុម និងឃុំក្បាលរមាស មិនសូវងាយនឹងកើតមានភ្លើងឆេះព្រៃដោយស្ថិតនៅកម្រិត "ទាបខ្លាំង" (WAI=0,0៣ និង WAI=0,១២ រៀងគ្នា) ខណៈដែលឃុំកញ្ជរមានចំនួនច្រើនពីការឆ្លើយតបនៅក្នុងកម្រិត "មធ្យម" (WAI=0,៤៥)។

អនុប្រធានភូមិអូរណា ក្នុងខេត្តមណ្ឌលគិរី សង្កត់ធ្ងន់ថា ការបាត់បង់ព្រៃឈើ គឺជាមូលហេតុចម្បងមួយ ដែលបណ្តាលឱ្យមានការប្រែប្រួលធាតុអាកាសនៅក្នុងតំបន់ ជាពិសេស ធ្វើឱ្យមានការកើនឡើងនៃសីតុណ្ហភាពកាន់តែគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះ រដូវវស្សា និងរដូវប្រាំងបានប្រែប្រួលទៅជារដូវមិនទៀងទាត់។ បញ្ហាភាពរាំងស្ងួតជាធម្មតាកើតឡើង ពីខែមករា ដល់ខែមេសា ហើយបានប៉ះពាល់យ៉ាងខ្លាំង ដល់ដំណាំរួមនៅក្នុងភូមិ រួមមាន ស្វាយចន្ទី ដំឡូងមី កៅស៊ូ សណ្តែក និងពោត។ កសិករដាំដំឡូងមីទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីភាពរាំងស្ងួត ដោយសារដំឡូងមីមិនអាចរស់បានក្នុងសីតុណ្ហភាពខ្ពស់ ដែលជាហេតុធ្វើឱ្យកសិករត្រូវដាំដំណាំនោះឡើងវិញច្រើនដង។ បន្ទាប់ពីខែមេសា ភ្លៀងធ្លាក់ខ្លាំងក៏បានបំផ្លាញដំឡូងមីយ៉ាងធ្ងន់ធ្ងរ ហើយសត្វចង្រៃក៏កើតមានឡើង។ ការដាំដំណាំកាលសម័យមុនដោយពឹងផ្អែកលើការអនុវត្តកសិកម្មបែបប្រពៃណី ដែលអាកាសធាតុ និងលក្ខខណ្ឌធម្មជាតិបានដើរតួយ៉ាងសំខាន់ ពេលនេះមិនអាចប្រើបានទៀតទេ។ ដីនេះធ្លាប់មានជីជាតិខ្លាំង ប៉ុន្តែឥឡូវក៏បានក្លាយជាដីគ្មានជីជាតិ។

### ៤.៣. សមត្ថភាពបន្សាំ

ភាពងាយរងគ្រោះនៃសហគមន៍មូលដ្ឋាន អាស្រ័យទៅលើកម្រិតនៃភាពប្រឈម ហើយនឹងសមត្ថភាពទប់ទល់របស់ប្រជាជន ទៅនឹងផលប៉ះពាល់។ យុទ្ធសាស្ត្រទប់ទល់រួមមាន ការទទួលបានធនធានសហគមន៍ ឬ សេវាសាធារណៈ ការដោះស្រាយផលប៉ះពាល់ ការចូលរួមក្នុងការអភិវឌ្ឍផែនការឃុំ សង្កាត់ និង ការគាំទ្រ និងការទទួលបានព័ត៌មានធាតុអាកាស និងអាកាសធាតុ។

#### *៤.៣.១ លទ្ធភាពទទួលបានធនធានតាមឃុំ*

រូបភាពទី១១ បង្ហាញនូវទិដ្ឋភាពទូទៅនៃកម្រិតលទ្ធភាពទទួលបានធនធានសំខាន់ៗជាច្រើន នៅតាមឃុំចំនួនបីដែលត្រូវបានធ្វើអង្កេត។ ទិន្នន័យបង្ហាញពីវិសាលភាពដែលអ្នកឆ្លើយសំណួរនៅក្នុងឃុំទាំងនេះអាចទទួលបានសេវាកម្មជាក់លាក់ដែលមានសារៈសំខាន់សម្រាប់សុខុមាលភាពនិងការអភិវឌ្ឍរបស់ពួកគេ។ការវិភាគបង្ហាញឱ្យឃើញពីនិន្នាការដែលភាគច្រើននៃអ្នកឆ្លើយសំណួរ នៅក្នុងឃុំនីមួយៗ រីករាយជាមួយការទទួលបានសេវាចម្រុះនៅក្នុងមូលដ្ឋានរបស់ពួកគេ។ សេវាកម្មដែលមិនអាចខ្វះបានទាំងនេះ រួមមាន សេវារដ្ឋបាល ការផ្គត់ផ្គង់អគ្គិសនី ទីផ្សារក្នុងស្រុក ស្ថាប័នអប់រំ និងមណ្ឌលថែទាំសុខភាព។

ទោះជាយ៉ាងណាក្តី ទិន្នន័យក៏បង្ហាញពីភាពខុសគ្នាជាក់លាក់អំពីលទ្ធភាពប្រើប្រាស់ធនធានទាំងនោះជាប្រចាំផងដែរ។ ទោះជាមានទស្សនៈវិជ្ជមាន តែធនធានមួយចំនួននៅតែទទួលបានតិចតួច។ គួរកត់សម្គាល់ថា តួលេខនេះបង្ហាញពីភាគរយទាបនៃអ្នកឆ្លើយសំណួរនៅឃុំទាំងបី ដែលមានលទ្ធភាពអាចប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។ អត្រានៃលទ្ធភាពក្នុងការទទួលបានការប្រើប្រាស់ ត្រូវបានកត់សម្គាល់ក្នុងកម្រិត ៣២,៥% ក្នុងឃុំកញ្ជរ ២៨,៨% សម្រាប់ឃុំស្រែខ្ទុម និងត្រឹមតែ ១,៣% ប៉ុណ្ណោះសម្រាប់ឃុំក្បាលរមាស។ ការស៊ើបអង្កេតបន្ថែមលើទិន្នន័យបង្ហាញពីក្តីកង្វល់សំខាន់មួយទៀតនោះ គឺលទ្ធភាពប្រើប្រាស់ទឹកស្អាត នៅមានកម្រិតនៅឡើយ។ ខណៈពេលដែលអ្នកឆ្លើយសំណួរភាគច្រើននៅក្នុងឃុំនីមួយៗ មានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ តួលេខនៅតែបង្ហាញពី កង្វះទឹកស្អាតក្នុងឃុំស្រែខ្ទុម និងឃុំក្បាលរមាស។ ១៥% ក្នុងចំណោមឆ្លើយសំណួរនៅក្នុងឃុំនីមួយៗ អាចមានលទ្ធភាព ទទួលបានទឹកស្អាត។

រូបភាពទី១១៖ លទ្ធភាពទទួលបានធនធានតាមឃុំ-សង្កាត់ (គិតជា%)




ប្រភព៖ ការស្ទង់មតិ ខែកក្កដា ឆ្នាំ២០២៣

តំណាងអង្គការមិនមែនរដ្ឋាភិបាលបានស្នើថា ការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស គឺចាំបាច់ សម្រាប់កសិករក្នុងស្រុកជាពិសេសជំនួយផ្នែកប្រព័ន្ធធារាសាស្ត្រដែលទាមទារឱ្យមានការកែលម្អដោយពិចារណាលើការផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធភាពសម្រាប់សកម្មភាពកសិកម្ម អគ្គិសនី ដែលត្រូវការដើម្បីផ្គត់ផ្គង់ទឹកដល់គ្រួសារនីមួយៗ។

បញ្ហាប្រឈមមួយទៀតដែលត្រូវដោះស្រាយ គឺទីផ្សារ។ អ្នកភូមិផលិត និងផ្គត់ផ្គង់បន្លែសរីរាង្គទៅកាន់ទីផ្សារក្នុងស្រុក តាមរយៈគំនិតផ្តួចផ្តើមសហគមន៍គោព្រៃ។ កសិករក៏កំពុងកៀងគរធនធានក្នុងខេត្តមណ្ឌលគិរី ដើម្បីអភិវឌ្ឍសហគមន៍ផ្លែបឺរ ដោយគិតពីភាពសម្បូរបែបនៃផ្លែបឺរពីកសិដ្ឋានក្នុងស្រុក។ សកម្មភាពបង្កើតប្រាក់ចំណូលទាំងនោះមានសារៈសំខាន់សម្រាប់អ្នកភូមិក្នុងតំបន់ក្នុងការផលិតដំណាំជាក់លាក់។ អ្នកភូមិក៏អាចធ្វើការ លើការផ្តល់ផលិតផលគុណភាពខ្ពស់សម្រាប់ទីផ្សារក្នុងស្រុក ហើយបន្ទាប់មកទៅដល់អ្នកផ្គត់ផ្គង់ ឆ្លងកាត់ព្រំដែន សម្រាប់ទីផ្សារអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ ហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូន គឺជាឧបសគ្គចម្បងសម្រាប់កសិករក្នុងស្រុកក្នុងការលើកកម្ពស់ផលិតផលក្នុងស្រុក។

### ៤.៣.២ ការចូលរួមអភិវឌ្ឍន៍ឃុំ

ក្នុងចំណោមអ្នកចូលរួមការស្ទង់មតិទាំងអស់ ជាងពាក់កណ្តាល (៦៤,២%) បានចូលរួមក្នុងសកម្មភាពជាច្រើនដើម្បីកែលម្អសហគមន៍មូលដ្ឋានរបស់ពួកគេ។ សូមមើលរូបភាពទី១២។ អ្នកចូលរួម ៦៥% បានចូលរួមកិច្ចប្រជុំដែលរៀបចំដោយឃុំ ខណៈក្រុមតូចជាង (១៤,១%) បានចូលរួមចំណែកក្នុងផែនការវិនិយោគរបស់ឃុំ។ ពីរបីនាក់ទៀតបានធ្វើការងារស្ម័គ្រចិត្ត ចូលរួមក្នុងយុទ្ធនាការ និងការតស៊ូមតិ ឬចូលរួមក្នុងសកម្មភាពផ្សេងទៀត។

កសិកម្មនៅឃុំស្រែខ្ទុម បានផ្លាស់ប្តូរពីកសិកម្មបែបប្រពៃណី មកជាកសិកម្មបែបបច្ចេកទេស ដោយសារប្រជាពលរដ្ឋបានទទួលការគាំទ្រ បណ្តុះបណ្តាល និងសម្ភារៈពីអង្គការ WWF កម្ពុជា។ ស្ថានភាពសហគមន៍មានភាពប្រសើរឡើងច្រើនបើប្រៀបធៀបទៅនឹងមុនគម្រោងរេដបូក។ អង្គការរេដបូក និងអង្គការ WWF កម្ពុជាបានផ្តល់មូលនិធិធ្វើផ្លូវថ្នល់ សាលារៀន បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធ។ ឃុំធ្វើជាដៃគូជាមួយសមាគមអភិរក្សសត្វព្រៃ (WCS) Cambodia ដើម្បីអនុវត្តគម្រោងរេដបូក ដែលមានគោលបំណងលើកកម្ពស់ការអភិវឌ្ឍសហគមន៍ ដើម្បីកាត់បន្ថយអត្រាចំណាកស្រុក។ ភូមិអូររអាម អូរណា និងស្រែល្វី ក្នុងខេត្តមណ្ឌលគិរី គឺជាភូមិដែលទទួលបានអត្ថប្រយោជន៍ពីគម្រោងរេដបូក។WCS ក៏បានផ្តល់ឱកាសសម្រាប់គាំទ្រដល់ការអភិវឌ្ឍសហគមន៍ និងសកម្មភាពលើកកម្ពស់ការយល់ដឹង

ស្រដៀងគ្នា ដើម្បីដោះស្រាយការទន្ទ្រានដី។ បញ្ហារកស៊ីកាប់ឈើខុសច្បាប់ទាំងនេះ អាចនាំឱ្យមានការកាប់បំផ្លាញព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។ សហគមន៍រេដ បូក អាចទទួលបានពី ១០០០០ដុល្លារ ទៅ ៥០០០០ដុល្លារក្នុងមួយឆ្នាំ សម្រាប់ការការពារព្រៃឈើរបស់ពួកគេ។ នៅឆ្នាំ២០២៣ ឃុំទទួលបានជាង ៧០០០០ដុល្លារពីគម្រោងរេដបូក ដែលបានអនុវត្តនៅក្នុងភូមិចំនួន 3 ដែលត្រូវបានចាត់ថ្នាក់ជាតំបន់ការពារសហគមន៍ (CPA)។ WCS, WWF និងឃុំបានពិភាក្សា អំពីរបៀបដែលប្រាក់ដែលទទួលបានពីគម្រោងនេះ ឱ្យអាចប្រើប្រាស់បានដើម្បីលើកកម្ពស់ជីវភាពរបស់អ្នកភូមិតាមរយៈការធ្វើពិពិធកម្មជីវភាព និងការធ្វើកសិកម្មចិញ្ចឹមជីវិត។

រូបភាពទី១២៖ ការចូលរួមអភិវឌ្ឍន៍ឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

មេភូមិស្រែខ្ទុមរំពឹងថា នឹងកាត់បន្ថយការធ្វើចំណាកស្រុកដោយបង្កើនឱកាសការងារក្នុងស្រុក និងសកម្មភាពបង្កើតប្រាក់ចំណូល។ ប្រសិនបើអ្នកភូមិអាចរកប្រាក់ពីសហគមន៍បាន ពួកគេនឹងមិនចាំបាច់ធ្វើចំណាកស្រុកដើម្បីស្វែងរកប្រាក់ចំណូលនៅពេលអនាគត។ មេភូមិរំពឹងថា គម្រោងរេដបូក មន្ទីរបរិស្ថានខេត្ត និងអង្គការ WWF នឹងបន្តជួយដល់ភូមិ។ មន្ទីរបរិស្ថានខេត្ត និងការិយាល័យបរិស្ថានស្រុក ក៏បានលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងកំពុងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលដែលគាំទ្រផងដែរ។ ជាការពិតណាស់ ក្រុមប្រឹក្សាឃុំកំពុងធ្វើការដើម្បីកៀរគរធនធាន និងការគាំទ្រ ហើយមន្ទីរខេត្ត និងសាលាស្រុកកំពុងធ្វើការជាមួយក្រុមប្រឹក្សាឃុំ ដើម្បីអនុវត្តសកម្មភាពមួយចំនួន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការធ្វើចំណាកស្រុក។ ឧទាហរណ៍ មន្ទីរកសិកម្មខេត្តគ្រប់គ្រងគម្រោងកសិកម្មដែលបានស្នើឡើង [បទសម្ភាសន៍ជាមួយជនបង្គោលសំខាន់ៗ ជាមួយមេឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣]។

### ៤.៣.៣ តួនាទី និងទំនួលខុសត្រូវក្នុងការអភិវឌ្ឍសហគមន៍

ប្រជាជនដែលជាអ្នកចូលរួមក្នុងអង្កេត ក៏ត្រូវបានសាកសួរផងដែរ ទាក់ទងនឹងតួនាទីនៃការចូលរួមរបស់ពួកគេនៅក្នុងការប្រជុំសហគមន៍ ដូចដែលបានបង្ហាញក្នុងរូបភាពទី១៣។ ភាគច្រើននៃអ្នកឆ្លើយសំណួរ (៦៣,៨% នៅឃុំកញ្ជរ ៨២,២% នៅស្រែខ្ទុម និង ៨២,៨% នៅឃុំក្បាលរមាស) ត្រូវបានកំណត់ថា ជាអ្នកចូលរួមជាប់លាប់ក្នុងសកម្មភាពកិច្ចប្រជុំទាំងនេះ។ ផ្ទុយទៅវិញ មានតែមួយភាគតូចប៉ុណ្ណោះប្រហែលជាង ២,០% នៅក្នុងឃុំនីមួយៗ ដែលបានធ្វើអង្កេត ត្រូវបានសន្មតថាមានតួនាទីជាអ្នកធ្វើសេចក្ដីសម្រេចចិត្តក្នុងអំឡុងពេលកិច្ចប្រជុំទាំងនេះ។

រូបភាពទី១៣៖ តួនាទីសំខាន់ៗក្នុងការប្រជុំសហគមន៍តាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

### *៤.៣.៤ ការទទួលបានការគាំទ្រពីសហគមន៍*

អ្នកចូលរួមពីឃុំសិក្សា ក៏ត្រូវបានសាកសួរផងដែរអំពីជំនួយ ដែលពួកគេទទួលបានពីសហគមន៍ដូច ដែលបានរៀបរាប់ក្នុងរូបភាពទី១៤។ សរុបមក អ្នកចូលរួមភាគច្រើនដោយមិនគិតពីទីតាំងភូមិសាស្ត្ររបស់ពួកគេ បានបង្ហាញថាជំនួយដែលពួកគេត្រូវបានផ្តល់ឱ្យគឺខ្វះខាត។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ នៅក្នុងតំបន់កញ្ជរ ប្រមាណមួយភាគបី (៣៣,៣%) នៃអ្នកចូលរួមបានបង្ហាញថា ការគាំទ្រដែលពួកគេទទួលបាន គឺខ្វះខាត។ មួយផ្នែកដែលច្រើនជាង មានប្រមាណ (៦១,៩%) បានបង្ហាញពីជំហរអព្យាក្រឹត ហើយមានជាប្រភាគតូច (៤,៧%) បានពេញចិត្តនឹងជំនួយនោះ។

រូបភាពទី១៤៖ ការគាំទ្រក្នុងសហគមន៍




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

ផ្ទុយទៅវិញនៅតំបន់ស្រែខ្ទមមួយភាគធំ (ប្រហែល ៨១,៨%) នៃអ្នកចូលរួម បានបង្ហាញពីការមិនពេញចិត្ត ចំពោះកម្រិតនៃការគាំទ្រ ខណៈដែលត្រឹមតែ ៩,០% បានទទួលស្គាល់ភាពគ្រប់គ្រាន់នៃជំនួយនោះ។ ចំណែកឯនៅឃុំក្បាលរមាសវិញ គេសង្កេតឃើញថា ១៩,៣% នៃអ្នកឆ្លើយសំណួរបានបង្ហាញថាជំនួយ ដែលទទួលបានខ្វះខាតខ្លាំង ហើយ ២៩,០% ទៀតចាត់ទុកថានូវមានភាពខ្វះខាត។ នៅក្នុងតំបន់នេះ ប្រមាណជា ២៥,៨% នៃអ្នកឆ្លើយតប បានបង្ហាញថា ពួកគេសប្បាយរីករាយ ចំពោះការគាំទ្រដែលពួកគេបានទទួល។

### ៤.៣.៥ យុទ្ធសាស្ត្រឆ្លើយតប និងសមត្ថភាពបន្សាំខ្លួនរបស់សហគមន៍មូលដ្ឋាន

រូបភាពទី១៥ បង្ហាញពីវិធីសាស្ត្រផ្សេងៗ ដែលសហគមន៍មូលដ្ឋានប្រើប្រាស់ ដើម្បីដោះស្រាយការខាតបង់ដោយសារ អាកាសធាតុនៅក្នុងឃុំរៀងៗខ្លួន។ ឃុំនីមួយៗ បានបង្ហាញពីដំណោះស្រាយផ្សេងៗគ្នា ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ។ នៅក្នុងឃុំកញ្ជរ អ្នកចូលរួមជាទូទៅបានខ្ចីលុយនៅពេលដែលពួកគេជួបវិបត្តិហិរញ្ញវត្ថុ។ នៅក្នុងឃុំនេះ ក្នុងចំណោមអ្នកចូលរួមសរុប ២៨,១% បានជ្រើសរើសខ្ចីប្រាក់ពី MFI ឬធនាគារ។ ជាការប្រៀបធៀប ១១,០% បានស្វែងរកជំនួយហិរញ្ញវត្ថុពីអ្នកឱ្យខ្ចី ឬបុគ្គលឯកជន។ ជាងនេះទៅទៀត ប្រហែល ៩,៨% នៃអ្នកចូលរួមបាន ងាកទៅខ្ចីប្រាក់ពីមិត្តភក្តិ ឬក្រុមគ្រួសារ។ យុទ្ធសាស្ត្រដែលសហគមន៍ទទួលយក គឺការធ្វើចំណាកស្រុក ដែលមានអ្នកចូលរួមប្រហែល ១៨,៣% ធ្លាប់បានជ្រើសរើសយកជម្រើសនេះជា វិធីមួយដើម្បីដោះស្រាយកាលពីអតីតកាល។

ស្រដៀងគ្នាផងដែរ ក្នុងឃុំស្រែខ្ទម ការខ្ចីប្រាក់បានលេចចេញជាវិធីសាស្ត្រមួយដែលត្រូវបានជ្រើសរើសយកជាទូទៅមួយ។ ប្រមាណជា ២៦,៨% នៃអ្នកឆ្លើយតបដែលត្រូវបានធ្វើអង្កេតនៅក្នុងតំបន់នេះ បានទទួលប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឬធនាគារ ខណៈដែល ១៨,៥% បានស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុពីសាច់ញាតិ ឬមិត្តភក្តិ។ លើសពីនេះទៀត ការធ្វើចំណាកស្រុកត្រូវបានគេកំណត់ថាជាយុទ្ធសាស្ត្រដ៏សំខាន់មួយ ដោយអ្នកឆ្លើយសំណួរប្រហែល ២៥% នៅក្នុងឃុំនេះជ្រើសរើសសកម្មភាពនេះជាវិធីសាស្ត្រ។

ផ្ទុយទៅវិញ ឃុំក្បាលរមាស ហាក់ដូចជាមិនសូវមានដំណោះស្រាយជាក់ស្តែងរឹងមាំ សម្រាប់ដោះស្រាយការខាតបង់ ដែលបណ្តាលមកពីផលប៉ះពាល់អាកាសធាតុ ជាសមាមាត្រគួរឱ្យកត់សម្គាល់ (២៧,៩%) បង្ហាញថា ពួកគេមិនទាន់មានវិធីសាស្ត្រច្បាស់លាស់ណាមួយនៅឡើយ។ នៅក្នុងបរិបទនេះ ប្រហែល ២៦,៥% នៃអ្នកឆ្លើយសំណួរបានប្រើការសន្សំប្រាក់ ជាមធ្យោបាយកាត់បន្ថយការខាតបង់ ខណៈដែល ១០,៣% បានជ្រើសរើសនូវការធ្វើចំណាកស្រុកជាមធ្យោបាយនៃការទប់ទល់នឹងបញ្ហាដែលបានជួបប្រទះ។

រូបភាពទី១៥៖ របៀបដោះស្រាយរបស់សហគមន៍មូលដ្ឋាន ទៅនឹងការខាតបង់ដោយអាកាសធាតុតាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

យោងតាមបទសម្ភាសន៍ជនបង្គោលកាលពីខែកក្កដា ឆ្នាំ២០២៣ មេភូមិស្រែខ្ទុម ខេត្តមណ្ឌលគិរី បានសង្កត់ធ្ងន់ថា "ភូមិនេះបានរងផលប៉ះពាល់ដោយធាតុអាកាសស្ងួត និងក្តៅ។ ភូមិនេះនៅមិនទាន់មានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ឬយុទ្ធសាស្ត្របច្ចេកទេសទប់ទល់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅឡើយទេ។ អ្នកស្រុកខ្លះ នៅតែមានជំនឿលើការបន់ស្រន់សុំទឹកភ្លៀងពេលរាំងស្ងួត ដែលគ្មានទឹកសម្រាប់ធ្វើការកសិកម្ម"។ មេភូមិអូរណា ខេត្តមណ្ឌលគិរី លើកឡើងថា ថវិការបស់ឃុំគ្រាន់តែប្រើប្រាស់សម្រាប់ជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ និងស្ពាន) នៅក្នុងភូមិ មិនមែនសម្រាប់បញ្ហាចំណាកស្រុកនោះទេ។ ចំណែកវិស័យកសិកម្មត្រូវបានគាំទ្រដោយមូលនិធិស្រុក ឬមន្ទីរកសិកម្មខេត្ត។ ទន្ទឹមនឹងនោះ មន្ទីរបរិស្ថានខេត្តបាននឹងកំពុងធ្វើសកម្មភាព លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការកាប់បំផ្លាញព្រៃឈើនៅក្នុងភូមិ។ ភូមិនេះគឺជា សហគមន៍តំបន់ការពារ មួយក្នុងចំណោមសហគមន៍តំបន់ការពារផ្សេងទៀត ដែលបានចូលរួមក្នុង គម្រោងរេដបូក។ អនុប្រធានភូមិលើកឡើងថា គម្រោងរេដបូក បាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់នូវលំនាំនៃការធ្វើចំណាកស្រុក។ ទោះជាយ៉ាងណាក្តី ការកាត់បន្ថយការធ្វើចំណាកស្រុក ភាពធន់នឹងអាកាសធាតុ និងការពង្រីកវិស័យកសិកម្មនៅតាមជនបទ មិនត្រូវបានបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ភូមិនោះទេ។

### *៤.៣.៦ ប្រភពព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ*

រូបភាពទី១៦ បង្ហាញពីបណ្តាញព័ត៌មានផ្សេងៗ ដែលអ្នកឆ្លើយតបក្នុងតំបន់សិក្សាទាំងបីទទួលបាន ទាក់ទងនឹងអាកាសធាតុ។ តាមការធ្វើអង្កេតបង្ហាញថា ប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា ហ្វេសបុក និងតេឡេក្រាម គឺជាប្រភពព័ត៌មានចម្បងដែលបានប្រើប្រាស់ប្រមាណជា ៤០% នៃអ្នកចូលរួមក្នុងការអង្កេត។ ប្រភពបន្ទាប់ទី២ គឺប្រភពមកពីមិត្តភ័ក្តិ និងក្រុមគ្រួសារ ដោយមាន ៣៤,០% នៃអ្នកឆ្លើយសំណួរក្នុងឃុំកញ្ជូរ និងប្រហែល ២៨% នៃអ្នកមកពីឃុំក្បាលរមាស និងឃុំស្រែខ្ទុម ដែលអាស្រ័យព័ត៌មានតាមរយៈបណ្តាញនេះ។ ប្រភពព័ត៌មានទី៣ និងទី៤ គឺមានភាពប្រហាក់ប្រហែលគ្នាដូចជា ប្រព័ន្ធផ្សព្វផ្សាយធំៗ (រួមមានទូរទស្សន៍ វិទ្យុ និងកាសែត) ដែលមានប្រហែល ១០,០% និងការប្រមូលផ្តុំនៅក្នុងសហគមន៍ ដែលមានប្រហែល ៩,០%។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ ប្រភពផ្សេងទៀត ដូចជាអង្គការក្រៅរដ្ឋាភិបាល និងប្រព័ន្ធប្រកាសអាសន្នហាក់ដូចមិនមែនជាប្រភពព័ត៌មាន ដែលអ្នកឆ្លើយតបភាគច្រើនទូទៅទទួលបាននោះទេ។

រូបភាពទី១៦៖ ប្រភពព័ត៌មានអំពីការប្រែប្រួលអាកាសធាតុតាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

ក្នុងអំឡុងឆ្នាំ២០២១-២២ ផ្ទះចំនួន៩ខ្នង នៅក្នុងភូមិឆ្នែង ឃុំស្រែខ្ទុមបានរងការខូចខាត ដោយសារខ្យល់ព្យុះ និងរន្ទះ។ អ្នកភូមិនៅក្នុងសហគមន៍ ទទួលបានព័ត៌មានអំពីគ្រោះធម្មជាតិនេះតាមវិទ្យុ។ ប្រជាជននៅក្នុងភូមិមិនទាន់ទទួលបានដំណឹងជាមុនអំពីព្រឹត្តិការណ៍គ្រោះធម្មជាតិ និងមិនធ្លាប់ត្រូវបានបង្រៀនពីរបៀបដែលពួកគេអាចត្រៀមខ្លួន ឬឆ្លើយតបទៅនឹងព្រឹត្តិការណ៍គ្រោះធម្មជាតិដែលនឹងកើតឡើងនៅឡើយទេ។

## ៤.៤ កត្តាចម្បងមានឥទ្ធិពលលើការធ្វើចំណាកស្រុក

ការសិក្សាក៏បានសាកសួរអំពីមូលហេតុសំខាន់ៗ ដែលបណ្តាលឱ្យមនុស្សធ្វើការចំណាកស្រុក ដូចដែលបានបង្ហាញក្នុងរូបភាពទី១៧។ កត្តាចម្បងនៅទូទាំងតំបន់បីផ្សេងគ្នាដែលបានសិក្សា គឺផ្តោតលើភាពក្រីក្រ ដោយមានជាង ៣០,០% នៃអ្នកចូលរួមបានផ្តល់ការឆ្លើយតបនេះ។ កត្តាគួរឱ្យកត់សម្គាល់ផ្សេងទៀតរួមមាន ការមិនអាចរកការងារធ្វើនៅក្នុងស្រុក និងមានបំណុល។ ការសិក្សាក៏បានសង្កេតឃើញពីហេតុផល ដែលទាក់ទង នឹងការប្រែប្រួលអាកាសធាតុ។ ហេតុផលទាំងនេះរួមមានទិន្នផលដំណាំថយចុះ ៦,៦% ក្នុងឃុំក្បាលរមាស ៧,៦% ក្នុងឃុំស្រែខ្ទុម និង ៥,៥% ក្នុងឃុំកញ្ជរ។ អ្នកចូលរួមផ្តល់ការឆ្លើយតបក៏បានលើកឡើងអំពីមូលហេតុ គឺបណ្តាលមកពីគ្រោះរាំងស្ងួត និងទឹកមិនគ្រប់គ្រាន់ (៣,៦% ក្នុងឃុំក្បាលរមាស ២,៧% ក្នុងឃុំស្រែខ្ទុម និង ២,១% ក្នុងឃុំកញ្ជរ) និងភ្លៀងធ្លាក់ខ្លាំងពេកនាំឱ្យមានទឹកជំនន់ (៣,៦% ក្នុងក្បាលរមាស ១,៤% ក្នុងឃុំស្រែខ្ទុម និង ២,២% នៅឃុំកញ្ជរ)។

រូបភាពទី១៧៖ កត្តាចម្បងនៃការធ្វើចំណាកស្រុកតាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

តាមការយល់ឃើញអ្នកឆ្លើយតបក្នុងអង្កេត បានរកឃើញថាមាន៥កត្តាសំខាន់ៗ មានឥទ្ធិពលលើការធ្វើចំណាកស្រុក។ រូបភាពទី១៨ បង្ហាញពីកត្តាសេដ្ឋកិច្ចរួមចំណែកខ្ពស់បំផុតក្នុងការជម្រុញឱ្យមាននូវការធ្វើចំណាកស្រុក (ឃុំកញ្ជរ ៥៩,៩% ឃុំស្រែខ្ទុម ៦៣,២% និងក្បាលរមាស ៥២,៥%) ដោយបន្ទាប់មក កត្តាសង្គម និងវប្បធម៌ សម្រាប់ឃុំកញ្ជរ ២៩,១% ឃុំស្រែខ្ទុម ២៧,៨% និង ឃុំក្បាលរមាស ២៨,១%។ អង្កេតនេះបានបង្ហាញថា កត្តាបរិស្ថានបានរួមចំណែកតិចតួចដល់ការធ្វើចំណាកស្រុក ដែលមានចំនួន ៥,១% នៅឃុំកញ្ជរ ៤% នៅឃុំស្រែខ្ទុម និង ៧,១% នៅឃុំក្បាលរមាស។

ការខាតបង់សេដ្ឋកិច្ច និងការខូចខាតទាក់ទងនឹងដំណាំកសិកម្មដោយការប្រែប្រួលអាកាសធាតុ គឺជាមូលហេតុចម្បងនៃការធ្វើចំណាកស្រុក។ កិច្ចសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋានបានបង្ហាញថា កង្វះជំនួយបច្ចេកទេសក្នុងវិស័យកសិកម្ម ទិន្នផលទាប និងបំណុលបានធ្វើឱ្យប្រជាពលរដ្ឋសម្រេចចិត្តធ្វើការចំណាកស្រុក ដើម្បីរកប្រាក់ចំណូល។ វាជាការពិតផងដែរ ដែលជនចំណាកស្រុកទៅក្រៅប្រទេស អាចរកបានប្រាក់ចំណូលខ្ពស់ ហើយផ្ញើប្រាក់ត្រឡប់មកផ្ទះវិញ។ មេភូមិអូរអាម ខេត្តមណ្ឌលគិរី លើកឡើងថា បើប្រៀបធៀបនឹងភូមិផ្សេងទៀតក្នុងតំបន់ មានជនចំណាកស្រុកតិចតួចប៉ុណ្ណោះ ប្រមាណជា ៥% នៃចំនួនសរុប ៨០២គ្រួសារ នៅក្នុងភូមិអូរអាម ដោយសារអ្នកភូមិមានជីវភាពប្រសើរជាងមុន និងមានចំណេះដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងផលវិបាកនៃការធ្វើចំណាកស្រុក។ បញ្ហាសេដ្ឋកិច្ច និងកង្វះដីកសិកម្ម គឺជាបញ្ហាចម្បងដែលធ្វើឱ្យមានជនចំណាកស្រុកចាកចេញទៅរកការងារធ្វើ។ ជាធម្មតា អ្នកភូមិធ្វើចំណាកស្រុកក្នុងរយៈពេលខ្លីដើម្បី រកដំណោះស្រាយជីវភាពមួយគ្រា។ ភាគច្រើននៃចំណាកស្រុកទាំងនោះ ធ្វើចំណាកស្រុកតាមរដូវ គឺនៅពេល ដែលរដូវប្រមូលផលត្រូវបានបញ្ចប់។ ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដូចជា ទឹកជំនន់នៅក្នុងភូមិបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណាំកៅស៊ូ និងដំណាំដំឡូងមី [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយមេភូមិអូរអាម ឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៣]។

រូបភាពទី១៨៖ កត្តាដែលប៉ះពាល់ដល់ការធ្វើចំណាកស្រុកតាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

ស្រដៀងគ្នានេះដែរ មេឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី យល់ឃើញថា មូលហេតុនៃការធ្វើចំណាកស្រុករួមមាន ទិន្នផលកសិកម្មទាប និងបំណុលរបស់ប្រជាពលរដ្ឋ។ ទិន្នផលទាបកើតឡើងបណ្តាលមកពីហេតុផលទាក់ទងនឹងអាកាសធាតុ ដោយកសិករនៅក្នុងឃុំធ្វើកសិកម្មដែលផ្អែកលើទឹកភ្លៀង។ ជាពិសេសភ្លៀងធ្លាក់ខុសរដូវធ្វើឱ្យខូចដល់ការចេញផ្ការបស់ស្វាយចន្ទី ខណៈភាពរាំងស្ងួតបំផ្លាញដំណាំកៅស៊ូ។ អាស្រ័យហេតុនេះ កសិករត្រូវចំណាយដើមទុនបន្ថែមក្នុងការដាំដុះដំណាំទាំងនោះឡើងវិញ [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយមេឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣]។ ជាការបញ្ជាក់បន្ថែមលើការរកឃើញនេះអ្នកភូមិឡាប៉ាខេ បានមើលឃើញថា ភាពរីកចម្រើនយឺតយ៉ាវផ្នែកហិរញ្ញវត្ថុ ភាពខ្វះខាតប្រព័ន្ធស្រោចស្រពសម្រាប់ការធ្វើកសិកម្ម និងការគ្មានដីជាមូលហេតុចម្បងនៃការធ្វើចំណាកស្រុក។ "មូលហេតុនៃការធ្វើចំណាកស្រុក គឺបញ្ហាហិរញ្ញវត្ថុជាចម្បង"។ អ្នកភូមិនៅតែពឹងផ្អែកលើទឹកភ្លៀងសម្រាប់ការដាំដុះ ដោយសារមិនមានប្រព័ន្ធធារាសាស្ត្រ... ជនចំណាកស្រុកមិនមានដីសម្រាប់ប្រើប្រាស់យូរអង្វែង...

ជនចំណាកស្រុកស្វែងរកការងារធ្វើនៅទីក្រុងភ្នំពេញ និងទីក្រុងផ្សេងទៀតក្នុងរយៈពេលខ្លី" [បទសម្ភាសន៍ជនបង្គោលសំខាន់ជាមួយមេភូមិឡាប៉ាខេ ឃុំស្រែខ្ទុម ខេត្តមណ្ឌលគិរី ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣]។

តំណាងអង្គការមិនមែនរដ្ឋាភិបាលបានបង្ហាញឱ្យដឹងថា គ្រួសារភាគច្រើននៅក្នុងខេត្តមណ្ឌលគិរី មានយ៉ាងហោចណាស់មនុស្សម្នាក់ ដែលស្ថិតក្នុងក្រុមអាយុធ្វើការ ហើយទំនងជាធ្វើការចំណាកស្រុកដើម្បីរកការងារធ្វើ។ អ្នកតំណាងរូបនេះយល់ឃើញថា មូលហេតុនៃការធ្វើចំណាកស្រុកមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹង ការប្រែប្រួលអាកាសធាតុដែលបណ្តាលឱ្យដីខ្សត់ជីជាតិ និងធ្វើឱ្យបាត់បង់ទិន្នផលកសិកម្ម។

## ៤.៥ ការផ្លាស់ប្តូរលំនាំជីវភាពរស់នៅ និងមូលហេតុ

មួយចំនួនធំនៃអ្នកឆ្លើយតបក្នុងអង្កេត (៦៧,១%) នៅក្នុងឃុំគោលដៅទាំងបី បានបញ្ជាក់ថា សមាជិកគ្រួសាររបស់ពួកគេត្រូវបានរងផលប៉ះពាល់ដោយព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ដែលបានបំផ្លាញនូវទ្រព្យសម្បត្តិ ឬសម្ភារប្រើប្រាស់ ដំណាំគ្រប់ប្រភេទ បសុសត្វ ហើយនាំឱ្យបាត់បង់ប្រាក់ចំណេញ និងមានការចំណាយលើការថែទាំសុខភាពបន្ថែមទៀត។ រូបភាពទី១៩ បានបង្ហាញពីការយល់ដឹងអំពីកត្តាដែលរួមចំណែកដល់ភាពអន់ថយនៃមធ្យោបាយរស់នៅរបស់អ្នកឆ្លើយតប។ មូលហេតុចម្បងដែលរកឃើញនៅក្នុងតំបន់សិក្សាទាំងបី គឺកើតចេញពីការថយចុះនៃផលិតភាពដែលបណ្តាលមកពីការថយចុះនៃកម្លាំងការងារដែលធ្លាប់មានពីមុនមក។ នៅឃុំស្រែខ្ទុម និងឃុំក្បាលរមាស ទិន្នផលមិនគ្រប់គ្រាន់ គួបផ្សំនឹងការបាត់បង់ដំណាំ និងបសុសត្វ ដោយសារព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ ដូចជា ភ្លៀងធ្លាក់ខ្លាំង សីតុណ្ហភាពខ្ពស់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ឬការផ្ទុះរាតត្បាតសត្វល្អិត ជាកត្តាបន្ថែមដែលរួមចំណែកដល់ការធ្លាក់ចុះនៃការគាំទ្រពីសហគមន៍។ ទន្ទឹមនឹងនោះ នៅឃុំកញ្ជូរ និន្នាការជាក់ស្តែងកើតឡើងនៅក្នុងមូលដ្ឋាន គឺមកពីការធ្លាក់ចុះនៃអាជីវកម្ម ដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរស់នៅទាំងមូលក្នុងតំបន់។ ប្រមាណជាមួយភាគបួននៃអ្នកចូលរួមឆ្លើយសំណួរក្នុងឃុំទាំងបី ក៏បានយល់ឃើញពីកត្តាផ្សេងៗទៀតដែរ រួមមាន មិនសូវមានឱកាសការងារ ការជំពាក់បំណុល ធាតុចូលកសិកម្មមានតម្លៃថ្លៃ ផលិតផលកសិកម្មមានតម្លៃថោក ឬគ្មានទីផ្សារ ផលវិបាកនៃការអភិវឌ្ឍទំនប់វារីអគ្គិសនី បញ្ហាសុខភាព និងបន្ទុកគ្រួសារ។ ចាប់ពីឆ្នាំ ២០២០ ផលិតភាពកសិកម្មសម្រាប់ដំណាំដូចជា ស្វាយចន្ទី ដំឡូងមី និងកៅស៊ូមានកម្រិតទាប ដោយសារគ្រោះរាំងស្ងួតមិនទៀងទាត់ក្នុងខែមិថុនា ដល់ខែកក្កដា។ កត្តានេះបានប៉ះពាល់ដល់ជីវភាពកសិករយ៉ាងខ្លាំង។

រូបភាពទី១៩៖ មូលហេតុនៃការផ្លាស់ប្តូរជីវភាពតាមឃុំ (គិតជា%)




ប្រភព៖ អង្កេតតាមគ្រួសារ ខែកក្កដា ឆ្នាំ២០២៣

# ៥. ការពិភាក្សា

## ៥.១ ផលប៉ះពាល់រយៈពេលវែងនៃការប្រែប្រួលអាកាសធាតុ

ប្រជាជនក្នុងតំបន់បានជួបប្រទះនូវព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរដូចជា សីតុណ្ហភាពខ្ពស់ ទឹកជំនន់ គ្រោះរាំងស្ងួត ការផ្លាស់ប្តូររដូវ ខ្យល់ព្យុះ ការផ្ទុះរាតត្បាតសត្វល្អិត និងភ្លើងឆេះព្រៃ។ កម្រិតនៃការយល់ឃើញនៃផលប៉ះពាល់មានចាប់ពីកម្រិតមធ្យមទៅខ្ពស់។ ឃុំក្បាលរមាស ក្នុងខេត្តស្ទឹងត្រែង ហាក់បីដូចជាមានភាពប្រឈមទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ជាពិសេសខ្យល់ព្យុះ ទឹកជំនន់ ការរាតត្បាតសត្វល្អិត សីតុណ្ហភាពខ្ពស់ និងភ្លើងឆេះព្រៃ។ ឃុំស្រែខ្ទុម ក្នុងខេត្តមណ្ឌលគិរី ប្រឈមមុខខ្លាំងទៅនឹងការរាតត្បាតសត្វល្អិត និងសីតុណ្ហភាពខ្ពស់ ខណៈដែល ឃុំកញ្ជរ ក្នុងខេត្តក្រចេះ ហាក់មិនសូវមានភាពប្រឈមខ្លាំងទៅនឹងព្រឹត្តិការណ៍ទាំងអស់នេះ។

ក្នុងការសិក្សានេះ អ្នកភូមិថ្នាក់មូលដ្ឋានបានសង្កត់ធ្ងន់លើបទពិសោធន៍របស់ពួកគេ ជាមួយនឹងសីតុណ្ហភាពខ្ពស់ជាអថេរមួយ នៃអថេរអាកាសធាតុ ដែលជារឿយៗកើតឡើងក្នុងអំឡុងចុងខែកុម្ភៈ ដល់ខែឧសភា នៅក្នុងឃុំកញ្ជរ និងឃុំស្រែខ្ទុម និងចាប់ពីខែមីនា ដល់ខែឧសភា នៅឃុំក្បាលរមាស។ វាដូចគ្នានឹងការរកឃើញរបស់ Heng (២០១៥) ដែលរកឃើញថា សីតុណ្ហភាពនៅកម្ពុជាបានកើនឡើង ០,៨°C តាំងពីឆ្នាំ១៩៥០ ក្នុងអត្រា ០,០២៣°C ក្នុងមួយឆ្នាំ។ ដូចគ្នានេះដែរ Lonn et al (ឆ្នាំ២០២១) បានរកឃើញថាកម្តៅខ្លាំងកំពុងកើនឡើង (ចន្លោះពី ៣៣°C និង ៤២°C ក្នុងឆ្នាំ២០១៩) ពិសេសនៅរដូវប្រាំង រវាងខែមីនា និងមេសា ដែលខ្ពស់ជាងកាលពីទសវត្សរ៍ឆ្នាំ១៩៩០ (៣៣°C និង ៣៨°C)។ គួបផ្សំនឹងការពន្យារពេលទឹកភ្លៀង កម្តៅខ្លាំងដាក់បន្ទុកគ្រួសារងាយរងគ្រោះ បង្ខំពួកគេឱ្យ បោះបង់ចោលការអនុវត្តកសិកម្ម និងបច្ចេកទេសកសិកម្មឆ្លាតវៃដែលបានផ្តល់ដោយអន្តរាគមន៍កម្មវិធី (Lonn et al., ២០២១)។

ការសិក្សានេះក៏បង្ហាញដែរថា ទឹកជំនន់ទន្លេកើតឡើងញឹកញាប់ចាប់ពីខែកក្កដា ដល់ខែតុលា នៅក្នុងឃុំកញ្ជរ ហើយទឹកជំនន់កើតឡើងជាញឹកញាប់ នៅក្នុងឃុំស្រែខ្ទុមចាប់ពីដើមខែមិថុនា ដល់ចុងខែកញ្ញានៅក្នុងឃុំក្បាលរមាស។ ការរកឃើញនេះស្របនឹងការសិក្សាផ្សេងទៀត (ឧទាហរណ៍ Rom et al., ២០២២; Try et al., ២០២៣) ដែលបង្ហាញថា ទឹកជំនន់កាន់តែធ្ងន់ធ្ងរ និងញឹកញាប់។ មូលហេតុចម្បងដែលធ្វើឱ្យមានទឹកជំនន់ត្រូវបានគេកំណត់ថា ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទន្លេ និងការផ្លាស់ប្តូរការប្រើប្រាស់ដី ជាពិសេសសម្រាប់ផលិតកម្មកសិកម្ម (Rom et al., ២០២៣)។

នៅក្នុងឃុំដែលបានសិក្សា គ្រោះរាំងស្ងួតតែងតែកើតមានពេញមួយឆ្នាំ ចាប់ពីខែមករា ដល់ខែធ្នូ។ ទោះយ៉ាងណាក៏ដោយ គ្រោះរាំងស្ងួតធ្ងន់ធ្ងរកើតឡើងពីខែមីនា ដល់ខែឧសភានៅក្នុងឃុំកញ្ជរ និងឃុំក្បាលរមាស និងចាប់ពីខែមីនាដល់ខែមិថុនានៅក្នុងឃុំស្រែខ្ទុម។ កសិករនៅក្នុងភូមិគោលដៅទាំងអស់បានជួបប្រទះនូវផលិតភាពកសិកម្មទាប ជាពិសេសគ្រាប់ស្វាយចន្ទី ដំឡូងមី និងកៅស៊ូ ដែលបណ្តាលមកពីគ្រោះរាំងស្ងួតខុសរដូវ។ ទន្ទឹមនឹងភាពតានតឹងនៃកម្តៅ តំបន់អាងទន្លេមេគង្គក្រោមរបស់កម្ពុជា ងាយប្រឈមនឹងគ្រោះរាំងស្ងួត ដែលប៉ះពាល់យ៉ាងខ្លាំងដល់ទឹក កសិកម្ម និងការប្រើប្រាស់ក្នុងស្រុក (Sithirith, ២០២១; Miyan, ២០១៥)។

បន្ថែមពីលើទឹកជំនន់ និងគ្រោះរាំងស្ងួត អ្នកឆ្លើយតបនៅក្នុងឃុំសិក្សាទាំង៣ ក៏ជួបប្រទះនូវព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរផ្សេងទៀត នៅពេលផ្សេងៗគ្នានៃឆ្នាំផងដែរ។ ពួកគេបានទទួលស្គាល់ថា លំនាំទឹកភ្លៀងតាមរដូវកាលប្រែប្រួលពីខែមេសា ដល់ខែកក្កដា។ អ្នកភូមិក្នុងឃុំកញ្ជរ ជួបប្រទះនឹងខ្យល់កន្ត្រាក់ ចាប់ពីខែមេសា ដល់ខែកក្កដា និងពីខែឧសភា ដល់ខែសីហា នៅក្នុងឃុំស្រែខ្ទុម ចំណែកឃុំក្បាលរមាស ប្រឈមនឹងព្រឹត្តិការណ៍នេះក្នុងខែមេសា និងឧសភា។ ការផ្ទុះរាតត្បាតសត្វល្អិតកើតឡើងក្នុងខែមិថុនា និងកក្កដា នៅក្នុងឃុំកញ្ជរ និងម្តងម្កាលក្នុងខែមិថុនា ក្នុងឃុំស្រែខ្ទុម ប៉ុន្តែវាកើតឡើងញឹកញាប់ជាងពីខែឧសភា ដល់ខែសីហា នៅក្នុងឃុំក្បាលរមាស។ ជាចុងក្រោយ ភ្លើងឆេះព្រៃជាធម្មតាកើតឡើងនៅគ្រប់ឃុំសិក្សាទាំងបីពីខែមករា ដល់ខែមេសា។

## ៥.២ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវភាពរស់នៅជនបទ

ការសិក្សានេះរកឃើញថា ការប្រែប្រួលអាកាសធាតុប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រភពចំណូល និងជីវភាពរស់នៅរបស់អ្នកភូមិ។ នៅក្នុងឃុំកញ្ជរ និងឃុំក្បាលរមាស ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺមិនអាចទាយទុកជាមុនបានឡើយ ដោយសារធាតុអាកាសនៅតែបន្តផ្លាស់ប្តូរ ដែលបណ្តាលឱ្យមានទឹកកាន់តែតិចសម្រាប់កសិកម្មក្នុងតំបន់បើធៀបនឹងកាលពីដប់ឆ្នាំមុន។ គ្រោះរាំងស្ងួតបានបណ្តាលឱ្យសត្វងាប់ ខណៈទឹកជំនន់ (ការបំផ្លិចបំផ្លាញធ្ងន់ធ្ងរបំផុតបានកើតឡើងក្នុងឆ្នាំ២០១៨-២០១៩) បានបង្កការខូចខាតដល់គ្រួសារដែលរស់នៅតាមដងទន្លេ និងបំផ្លាញប្រព័ន្ធធារាសាស្ត្រ នៅតំបន់មាត់ទន្លេពេញមួយឆ្នាំ។

ជាមួយនឹងផ្លាស់ប្តូរលំនាំធាតុអាកាស អ្នកស្រុកនៅក្នុងឃុំគោលដៅត្រូវប្រឈមមុខនឹងផលវិបាកជាច្រើនចំពោះការរស់នៅ និងជីវភាពរបស់ពួកគេ។ ការផ្លាស់ប្តូរ និងការខូចខាតបានធ្វើឱ្យទិន្នផលដំណាំធ្លាក់ចុះ បរិមាណត្រីស្រកចុះ និងកាត់បន្ថយប្រាក់ចំណូល។

